# បញ្ហាច្បាប់ និងយេនឌ័រ ក្នុងអាពាហ៍ពិពាហ៍ និងការលែងលះនៅប្រទេសកម្ពុជា

ដូរ៉េន វ៉ាន ឌី កី[១]

ទោះបីជាបទបញ្ញត្តិស្តីពីការរៀបអាពាហ៍ពិពាហ៍ និងការលែងលះនៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាមានអត្ថន័យគ្រប់គ្រាន់ជាផ្លូវការក៏ដោយ  រនាំងរីតត្បិតស្ត្រីក្នុងការទទួលបានផលប្រយោជន៍ពីសង្គមដែលកំណត់ដោយច្បាប់នៅតែមាន  ហើយនេះបណ្តាលឲ្យការការពារសិទ្ធិរបស់ស្ត្រីស្ថិតនៅបទដ្ឋានដែលស្ត្រីគួរទទួលបានសិទ្ធិ  និងយេនឌ័រ ។  ជាលទ្ធផល  ស្ថានភាពរបស់ស្ត្រីទាំងក្នុងអំឡុងពេលនៃចំណងអាពាហ៍ពិពាហ៍  និងនៅពេលមានការលែងលះ  តែងតែជួបប្រទះបញ្ហា ។  ដូច្នេះការពង្រឹងបទបញ្ញាឲ្យប្រសើរជាងមុនគឺជាការចាំបាច់ ។


១. សេចក្តីផ្តើម

២. អាពាហ៍ពិពាហ៍

២.១ លក្ខខ័ណ្ឌតម្រូវចំពោះបុគ្គលដែលមានសិទ្ធិរៀបអាពាហ៍ពិពាហ៍

២.២ ការចុះសំបុត្រអាពាហ៍ពិពាហ៍

២.៣ ទ្រព្យក្នុងចំណងអាពាហ៍ពិពាហ៍

២.៣.១. និយមន័យនៃទ្រព្យរួម

២.៣.២. ការចាត់ចែងទ្រព្យជាឯកតោភាគី

២.៣.៣. ការការពារចំពោះទីសំណាក់ដែលជាទ្រព្យដោយឡែក

២.៤. ការចំណាយក្នុងផ្ទះសម្បែង


---

[១] គឺជាមេធាវីសញ្ជាតិហូឡង់ម្នាក់ ដែលមានបទពិសោធន៍ ៩ ឆ្នាំក្នុងការប្រកបវិជ្ជាជីវៈច្បាប់ពាណិជ្ជកម្ម (ពន្ធសាជីវកម្ម និងគ្រួសារ) នៅប្រទេសហូឡង់ និងបទពិសោធន៍ ៦ ឆ្នាំធ្វើការលើបញ្ហាទាក់ទិននិងសិទ្ធិទទួលបាននីតិវិធីច្បាប់ត្រឹមត្រូវ និងយុត្តិធម៌នៅប្រទេសកម្ពុជា ដោយធ្វើការជាមួយអង្គការក្រៅរាជរដ្ឋាភិបាល ដែលមានឈ្មោះថា ជំនួយផ្នែកច្បាប់កម្ពុជា (Legal Aid of Cambodia) និងគម្រោងស្តីអំពីសិទ្ធិទទួលបាននីតិវិធីច្បាប់ត្រឹមត្រូវ និងយុត្តិធម៌ដល់ស្ត្រី របស់កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) ។ អត្ថបទនេះសរសេរឡើងដោយការជួយជាបច្ចេកទេសពីអង្គការក្រៅរាជរដ្ឋាភិបាលហៅថា ជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី (Legal Support for Children and Women) ។

២.៥. អំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈដោយសហព័ទ្ធ
២.៦. ទ្រព្យនូភាព និងការចុះបោលលំនៅសង្វាស
៣. ការលែងលះ
    ៣.១. សេចក្តីផ្តើម
    ៣.២. នីតិវិធី
៣.៣. ការបែងចែកទ្រព្យសម្បត្តិដែលមានក្នុងចំណងអាពាហ៍ពិពាហ៍
    ៣.៣.១ ដី
    ៣.៣.២ សិទ្ធិលើសោធននិវត្តន៍
៣.៤. អាហារកិច្ច
៣.៥. អំណាចមេបា សិទ្ធិទៅសួរសុខទុក្ខ និងអាហារកិច្ចឲ្យកូន
៣.៦. ការចាត់ចែងរក្សាការពារ
៤. អាពាហ៍ពិពាហ៍ និងការលែងលះដែលគ្មានសុពលភាពតាមផ្លូវច្បាប់
៤.១. អាពាហ៍ពិពាហ៍ដែលគ្មានសុពលភាពតាមផ្លូវច្បាប់
៤.២. ការលែងលះដែលគ្មានសុពលភាព
៤.៣. ភាពខុសគ្នារវាងច្បាប់ និងសង្គមជាក់ស្តែង
៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្តីផ្តើម

នៅប្រទេសកម្ពុជា ការរៀបអាពាហ៍ពិពាហ៍គឺជាប្រពៃណីទំនៀមទម្លាប់ដ៏មាន តម្លៃមួយនៅក្នុងសង្គម ។ ស្ថិតិពីឆ្នាំ ២០០៤ បង្ហាញថា ៨១ ភាគរយនៃស្ត្រីអាយុចាប់ពី ២៥ឆ្នាំ ដល់ ២៩ឆ្នាំ បានរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែ ៥ ភាគរយមិនរៀបអាពាហ៍ពិពាហ៍ឡើយក្នុងមួយជីវិតរបស់ពួកគេ[២] ។ ដោយសារតែការលែងលះជាទង្វើមួយដែលសង្គមមិនអាចទទួលយកបាន ដូច្នេះអាត្រានៃការលែងលះនៅមានកម្រិតទាបនៅឡើយ ។

[២] វិទ្យាស្ថានជាតិស្ថិតិ-ក្រសួងផែនការ, អង្កេតបន្ទោះជំរឿនប្រជាសាស្ត្រកម្ពុជាឆ្នាំ ២០០៤,មាននៅលើគេហទំព័រ http://nada.nis. gov.kh/ index.php/catalog/6 និង http://marriage-statistics.findthebest.com/l/1084/ Cambodia-2004-Women-Single ។

ថ្វីបើការរៀបអាពាហ៍ពិពាហ៍ជារឿងធម្មតា ប្រជាជនខ្មែរទូទៅពុំសូវដឹងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់សហព័ទ្ធក្នុងអំឡុងពេលនិងក្រោយពេលអាពាហ៍ពិពាហ៍ ។ ក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ ២០០៧ បានកំណត់យ៉ាងច្បាស់ពីចំណុចជាច្រើនទាក់ទងនឹងអាពាហ៍ពិពាហ៍ ចំណុចទាំងនោះមានដូចជាអាយុដែលអាចរៀបអាពាហ៍ពិពាហ៍ ការចុះសំបុត្រអាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិប្ដីប្រពន្ធ រួមទាំងសោហ៊ុយនៅក្នុងគ្រួសារ ។ លើសពីនេះទៅទៀត ច្បាប់ខ្មែរបានបន្ថែមការការពារលើស្ត្រីដែលរៀបអាពាហ៍ពិពាហ៍ ពីអំពើហិង្សាក្នុងក្រុមគ្រួសារ ទ្វេពន្ធភាព និងការបោះបោលពីសំណាក់ស្វាមីដោយគ្មានមូលហេតុត្រឹមត្រូវ[៣] ។ ទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តបទបញ្ញត្តិទាំងអស់នេះអាចនាំឲ្យមានបញ្ហាផ្នែកយេនឌ័រ ដែលបណ្ដាលឲ្យប្រសិទ្ធភាពក្នុងការពារសិទ្ធិស្ត្រីរបស់ក្រមរដ្ឋប្បវេណីមានការចុះអន់ថយ ។ ក្រមនេះក៏បានកំណត់អំពីផលវិបាកនៃការបញ្ចប់អាពាហ៍ពិពាហ៍ដែលបានចុះបញ្ជីតាមផ្លូវច្បាប់ ប៉ុន្តែមិនបានកំណត់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់សហព័ទ្ធ ដែលមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍របស់ខ្លួនទៅតាមផ្លូវច្បាប់នៅ ការិយាល័យចុះបញ្ជី ឬ សិទ្ធិរបស់ប្ដីប្រពន្ធរស់នៅបែកគ្នាដោយមិនបានលែងលះតាមតុលាការ ។ លទ្ធផលនៃការមិនចុះសំបុត្រអាពាហ៍ពិពាហ៍ និងទទួលបានដីកាលែងលះពីតុលាការអាចមានផលប៉ះពាល់ខ្លាំង ជាពិសេសទៅលើស្ត្រីជាប្រពន្ធ ។ ចំពោះទិដ្ឋភាពយេនឌ័រក្នុងអាពាហ៍ពិពាហ៍ និងការលែងលះនៅប្រទេសកម្ពុជា អ្នកនិពន្ធនឹងលើកយកមកពិភាក្សានៅចំណុចខាងក្រោម[៤] ។

## ២. អាពាហ៍ពិពាហ៍

ច្បាប់ខ្មែរកំណត់ចំណងអាពាហ៍ពិពាហ៍បានយ៉ាងត្រឹមត្រូវ និងអនុលោមតាមបទដ្ឋានអន្តរជាតិ ។ ក៏ប៉ុន្តែ ការអនុវត្ត ឬ ការមិនបានអនុវត្តន៍នៃច្បាប់ទាំងនេះ អាចមានផលប៉ះពាល់ច្រើនទៅ លើស្ត្រីដោយសារតែទំនៀមទំលាប់ប្រពៃណីក្នុងសង្គម ។

### ២.១ លក្ខខណ្ឌកំហិតជនដែលអាចរៀបអាពាហ៍ពិពាហ៍បាន

ក្នុងច្បាប់កម្ពុជា វិធានកំណត់ពីជនដែលអាចរៀបអាពាហ៍ពិពាហ៍ ខកខានមិនបានការពារទាំងបុរស និងនារីដូចដែលអ្វីពួកគេប៉ងចង់បាន ។ ច្បាប់ខ្មែរហាមឃាត់ការរៀបអាពាហ៍ពិពាហ៍វ័យ

[៣] សូមមើល ក្រមរដ្ឋប្បវេណីខ្មែរឆ្នាំ ២០០៧ មាត្រា ៩៧៨ (១) (ក) មាននៅលើគេហទំព័រ http://cambodianbusinesscorner. wordpress.com/2013/01/05/civil-code-2007/

[៤] មាត្រានេះមិនបានដោះស្រាយបញ្ហមរតកនៃប្រព័ន្ធច្បាប់សម្រាប់អាពាហ៍ពិពាហ៍ និងការលែងលះ ។

ក្មេងពេក ដោយបានកំណត់អាយុ ១៨ ឆ្នាំជាអាយុអប្បបរមាសម្រាប់ការរៀបអាពាហ៍ពិពាហ៍[៥] ។ មានករណី លើកលែងដែលអនុញ្ញាតឲ្យភាគីម្ខាងមានអាយុ ១៦ ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បាន[៦] ។ ប៉ុន្តែ នារីខ្មែរជាច្រើនរៀបការទាំងនៅវ័យក្មេង ដើម្បីគោរពតាមវប្បធម៌ និងទំនៀមទម្លាប់ប្រពៃណី ។ យោងទៅតាមស្ថិតិរបស់ UNICEP នៅឆ្នាំ ២០១៤ ២ ភាគរយនៃក្មេងស្រីទាំងអស់បាន រៀបអាពាហ៍ពិពាហ៍នៅអាយុ ១៥ ឆ្នាំ និង ១៨ ភាគរយផ្សេងទៀត រៀបការនៅពេល ពួកគេមានអាយុ ១៨ ឆ្នាំ[៧] ។ ដូច្នេះ តួលេខនេះបង្ហាញយ៉ាងច្បាស់ថាក្រមរដ្ឋប្បវេណីមិនត្រូវបាន យកមកប្រតិបត្តិឲ្យបានល្អប្រសើរនៅឡើយ ។

ក្រមរដ្ឋប្បវេណីហាមឃាត់នារីមិនឲ្យរៀបអាពាហ៍ពិពាហ៍ថ្មីទៀតបានឡើយ ប្រសិនបើ អំឡុងពេល ១២០ ថ្ងៃគិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុនត្រូវបានរំលាយ ឬ លុបចោល ពុំទាន់បាន កន្លងផុត[៨] ។ មាត្រានៃក្រមរដ្ឋប្បវេណីនេះមានគោលបំណងការពារសិទ្ធិបិតុភាពរបស់ប្តីដើម ។ គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) បានបង្ហាញពីការបារម្ភ ចំពោះបទបញ្ញត្តិនៃក្រមនេះ ដែលមានភាពរើសអើង និងដាក់កំហិតល័ក្ខខ័ណ្ឌហួសហេតុ ដោយមិនឲ្យស្ត្រីរៀបអាពាហ៍ពីពាហ៍ថ្មីបាន ពីព្រោះ សព្វថ្ងៃ បិតុភាពអាចបង្កើតបានយ៉ាងងាយស្រួលតាមរយៈការធ្វើតេស្តវេជ្ជសាស្ត្រសាមញ្ញមួយ[៩] ។ ទោះបីជាយ៉ាងណាក៏ដោយ ការធ្វើតេស្តវេជ្ជសាស្ត្រមិនអាចអនុវត្តបានទាំងស្រុងនៅក្នុងបរិបទរបស់ប្រទេសកម្ពុជា ។ ទីមួយ ការធ្វើតេស្ត ឌី.អិន.អេ (DNA) មិនសូវបានប្រើប្រាស់ទូលំទូលាយនៅកម្ពុជានៅឡើយ ហើយតម្លៃនៃការធ្វើតេស្តនេះមានតម្លៃខ្ពស់ហួសពីសមត្ថភាពរបស់ប្រជាជនកម្ពុជាដែលមានរហូតដល់ទៅជាង ៩៩ ភាគរយមិនអាចប្រើប្រាស់សេវានេះបាន ។ ទីពីរ នៅពេលស្ត្រីជិតសម្រាលកូនរៀបអាពាហ៍ពិពាហ៍ថ្មី ប្តីក្រោយនឹងត្រូវបាន

---

[៥] ក្រមរដ្ឋប្បវេណី, មាត្រា ៩៤៨ ។

[៦] ដូចខាងលើ, មត្រា ៩៤៨ (អាពាហ៍ពិពាហ៍អាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីអ្នកដែលមានអំណាចមេបា ឬ អាណាព្យាបាលរបស់អនីតិជន) ។

[៧] សូមមើលអត្ថបទដែលមានចំណងជើងថា អាពាហ៍ពិពាហ៍អនីតិជនជុំវិញពិភពលោក : ប្រទេសកម្ពុជា មាននៅលើគេហទំព័រ http://www.girlsnotbrides.org/child-marriage/cambodia/ ។

[៨] ក្រមរដ្ឋប្បវេណី, មាត្រា ៩៥០ ។

[៩] សូមមើលរបាយការណ៍ Concluding Observations on the Combined Fourth and Fifth Periodic Reports of Cambodia, CEDAW Comm., 56th Session, U.N. Doc. CEDAW/C/KHM/CO/4-5 at 9 (2013) ។

សន្មតដោយច្បាប់ថាជាឪពុករបស់កូននោះ[១០] ។ ប្តីមុនមិនអាចទាមទារបិតុភាព ទោះបីជាប្តីមុនពិតជាឪពុករបស់កូននោះក៏ដោយ ។

យ៉ាងណាមិញ បទបញ្ញត្តិនេះហាក់បីដូចជារំលោភលើជីវិតឯកជន និងរំលោភសិទ្ធិរបស់ស្ត្រី ។ ទីមួយ ការមិនអនុញ្ញាតឲ្យរៀបអាពាហ៍ពិពាហ៍ក្នុងរយៈពេល ១២០ ថ្ងៃ គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍ត្រូវបានរំលាយ ឬ លុបចោល ហាក់បីដូចជាមិនសមហេតុផល ពីព្រោះបទបញ្ញត្តិនេះមិនបានបំបាត់ចោលលទ្ធភាពដែលប្តីថ្មីក្លាយជាឪពុកស្របច្បាប់របស់ក្មេង ដែលជាកូនបង្កើតរបស់ប្តីមុនបានចាប់កំណើតនៅពេលណាមួយក្នុងអំឡុងពេល ១២០ ថ្ងៃ។ ប្រជាជនកម្ពុជាជាទូទៅជឿថារយៈពេលជាក់លាក់សម្រាប់ការមានផ្ទៃពោះគឺ ១២០ ថ្ងៃ ប៉ុន្តែជាការពិតជាក់ស្តែងរយៈពេលសម្រាប់មានគភ៌មានរហូតដល់ទៅ ២៨០ ថ្ងៃ។ ទីពីរ ម្តាយគឺជាមនុស្សដែលសក្តិសមជាងគេក្នុងការសម្រេចចិត្តថាតើប្តីថ្មីនេះគួរទទួលបានសិទ្ធិបិតុភាពតាមរយៈការរៀបអាពាហ៍ពិពាហ៍ឬយ៉ាងណា ពីព្រោះគាត់ជាមនុស្សតែមួយគត់ដែលអាចដឹងថានរណាជាឪពុកពិតប្រាកដ ។ ប្រសិនបើផ្អែកទៅតាមទស្សនៈសេរីភាពខាងផ្នែកនយោបាយ សង្គម និងច្បាប់ ស្ត្រីក៏ជាមនុស្សសក្តិសមបំផុតក្នុងការជ្រើសរើសរវាងដៃគូស្នេហាទាំងពីរនាក់ថាតើនរណាសមនឹងក្លាយជាឪពុកស្របច្បាប់ ដោយពិចារណាទៅលើផលប្រយោជន៍របស់កូនខ្លួនឯង ។ ក្នុងករណីដែលប្តីថ្មីបដិសេធបិតុភាព ជននោះអាចដាក់បណ្តឹងបដិសេធបិតុភាព[១១] ។

## ២.២ ការចុះសំបុត្រអាពាហ៍ពិពាហ៍

នៅប្រទេសកម្ពុជា អាពាហ៍ពិពាហ៍មួយអាចចាត់ទុកថាត្រឹមត្រូវតាមផ្លូវច្បាប់ លុះត្រាតែអាពាហ៍ពិពាហ៍នោះបានចុះសំបុត្រអាពាហ៍ពិពាហ៍ ដោយក្រុមប្រឹក្សាឃុំសង្កាត់[១២] ។ គូស្វាមីដែលមានគម្រោងនឹងរៀបការ អាចដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍នៅក្រុមប្រឹក្សាឃុំសង្កាត់នៃលំនៅដ្ឋានខាងស្រី ។ មន្ត្រីអត្រានុកូលដ្ឋាននៃក្រុមប្រឹក្សាឃុំសង្កាត់នឹងត្រួតពិនិត្យពាក្យសុំរៀប

---

[១០] សូមមើល ក្រមរដ្ឋប្បវេណី, មាត្រា ៩៨៨ ។

[១១] ដូចខាងលើ, មាត្រា ៩៨៩ ។

[១២] ការបកស្រាយធ្វើឡើងដោយផ្អែកទៅលើមាត្រា ៩៥៥ នៃក្រមរដ្ឋប្បវេណី និងអនុក្រឹត្យលេខ ១០៣ ស្តីពីអត្រានុកូលដ្ឋាន របស់ក្រសួងមហាផ្ទៃ មាននៅលើគេហទំព័រ http://www.skpcambodia.com/Laws%20&%20Regulations%20of%20the%20Kingdom%20of%20Cambodia/Nationality_Immergration_Civil%20Registration/Sub-dree%20No103%20on%20Civil%20Registration-Eng.pdf ។

អាពាហ៍ពិពាហ៍ ប្រសិនបើទទួលបានការយល់ព្រម ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ១ ច្បាប់ នឹងត្រូវបិទផ្សាយនៅសាលាឃុំសង្កាត់ខាងប្រុស និងមួយច្បាប់ទៀតនឹងបិទផ្សាយនៅលំនៅដ្ឋានខាងស្រីឲ្យបាន ១០ ថ្ងៃមុនពេលថ្ងៃរៀបអាពាហ៍ពិពាហ៍ ហើយបណ្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍អាចធ្វើបានក្នុង ថេរវេលា ១០ ថ្ងៃនេះ ។ ផុតរយៈពេល ១០ថ្ងៃ បុរស និងនារីត្រូវតែយល់ព្រមរៀបអាពាហ៍ពិពាហ៍ជាមួយគ្នានៅចំពោះមន្ត្រីអាត្រានុកូលដ្ឋានខាងលំនៅដ្ឋានរបស់នារី ។ ការយល់ព្រមនេះនឹងត្រូវចុះក្នុងសំបុត្រអាពាហ៍ពិពាហ៍ ។ នៅតាមបណ្តាខេត្តជាច្រើន ការចុះសំបុត្រអាពាហ៍ពិពាហ៍មានតម្លៃ ៤០០ រៀល[១៣] ។

## ២.៣. ទ្រព្យសម្បត្តិប្តីប្រពន្ធ

### ២.៣.១. និយមន័យនៃទ្រព្យសម្បត្តិរួម

ក្រមរដ្ឋប្បវេណីកម្ពុជាផ្តល់នូវប្រព័ន្ធដែលកំណត់ដោយច្បាប់យុត្តិធម៌មួយ សម្រាប់ទ្រព្យសម្បត្តិរបស់ប្តីប្រពន្ធ ។ ក្នុងករណីដែលប្តីប្រពន្ធមិនបានធ្វើកិច្ចព្រមព្រៀងមុនអាពាហ៍ពិពាហ៍ជាមួយគ្នានោះទេ ទ្រព្យសម្បត្តិរបស់ពួកគេនឹងត្រូវបានចាត់ចែកដោយប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ ។ ប្រព័ន្ធនេះបានចែកជាទ្រព្យសម្បត្តិរួមរាប់បញ្ចូលរាល់ទ្រព្យសម្បត្តិ ដែលប្តីប្រពន្ធទាំងសងខាង ឬ តែម្ខាងមាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែទ្រព្យសម្បត្តិ ដែលសហព័ទ្ធមាននៅមុនពេលរៀបអាពាហ៍ពិពាហ៍ ទ្រព្យសម្បត្តិដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម អច្ច័យទាន រួមទាំងទ្រព្យសម្បត្តិទាំងឡាយ ដែលទទួលបានពីការចាត់ចែងទ្រព្យសម្បត្តិដោយឡែកទាំងអស់នេះ[១៤] ។

ថ្វីបើក្រមរដ្ឋប្បវេណីបានផ្តល់ឲ្យនូវគោលការណ៍មិនលម្អៀងក៏ដោយ ចំណុចមួយចំនួននៃក្រមនេះនៅតែមានអត្ថន័យស្រពិចស្រពិល ។ ឧទាហរណ៍ ក្រមរដ្ឋប្បវេណីមិនបានចែងថា តើផលដែលកើតចេញពីទ្រព្យសម្បត្តិដោយឡែកត្រូវបានចាត់ទុកជាទ្រព្យសម្បត្តិប្តីប្រពន្ធដែរឬទេ ។

[១៣] អនុក្រឹត្យលេខ ៦២ ស្តីពីសោហ៊ុយនៃការចុះបញ្ជីអាត្រានុកូលដ្ឋាន និងត្រា (២០០២) ។

[១៤] សូមមើល ក្រមរដ្ឋប្បវេណី, មាត្រា ៩៧២ ដល់ មាត្រា ៩៧៣ ។

*ឧទាហរណ៍ ប្រពន្ធទទួលកេរមរតកចំនួន ១ ម៉ឺនដុល្លារសហរដ្ឋអាមេរិក និងបានដាក់លុយទាំងនោះទៅក្នុងធនាគារអេស៊ីលីដា ដោយទទួលបានការប្រាក់ប្រចាំឆ្នាំ ២ ភាគរយ ។*

*តើការប្រាក់នេះចាត់ទុកជាទ្រព្យសម្បត្តិប្តីប្រពន្ធដែរឬទេ? យោងទៅតាម ក្រមរដ្ឋប្បវេណី ការប្រាក់ប្រចាំឆ្នាំនេះត្រូវរាប់បញ្ចូលជាទ្រព្យសម្បត្តិប្តីប្រពន្ធ ។ ប៉ុន្តែដោយសារតែបញ្ហាអតិផរណា ប្រាក់ដើមនៃ ១ ម៉ឺនដុល្លារសហរដ្ឋអាមេរិកនឹងបាត់បង់តម្លៃរបស់វាច្រើនឆ្នាំក្រោយមក ។ ដូច្នេះហើយលទ្ធផលហាក់ដូចជាមិនសូវជាត្រឹមត្រូវ ។*

*ឧទាហរណ៍ ប្រសិនបើប្រពន្ធដាក់ដីដែលជាកេរដំណែលរបស់ខ្លួនជួល តើប្រាក់កម្រៃទទួលបានពីការជួលនេះត្រូវចាត់ទុកជាទ្រព្យសម្បត្តិប្តីប្រពន្ធ ឬ ទ្រព្យសម្បត្តិដោយឡែករបស់ប្រពន្ធ?*

យោងទៅតាមប្រព័ន្ធច្បាប់បច្ចុប្បន្ន ប្រាក់កម្រៃទទួលបានពីការជួលត្រូវបានសន្មតថាជាទ្រព្យសម្បត្តិរួម ពីព្រោះរាល់ទ្រព្យសម្បត្តិដែលទទួលបានក្នុងអំឡុងអាពាហ៍ពិពាហ៍ត្រូវចាត់ទុកជាទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ លើកលែងតែប្រទានសកម្ម ឬ ទ្រព្យសម្បត្តិ ទាំងឡាយទទួលបានដោយសន្តតិកម្ម ។ ទោះជាយ៉ាងណាក៏ដោយ ការកើនឡើងនៃតម្លៃដីក្នុងអំឡុងអាពាហ៍ពិពាហ៍មានប្រយោជន៍ដល់ភាគីខាងប្រពន្ធ ។ នៅពេលដីនេះលក់ ប្រាក់ចំណេញពីការលក់ត្រូវចាត់ទុកជាទ្រព្យសម្បត្តិដោយឡែករបស់ប្រពន្ធ ។

នៅមានការលំបាកជាច្រើនក្នុងការបែងចែកអចលនទ្រព្យ និងការកើនឡើងនៃតម្លៃអចលនទ្រព្យ ។ ឧទាហរណ៍ ប្រសិនបើប្រពន្ធទទួលមរតកជាភាគហ៊ុនយ៉ាងច្រើនពីក្រុមហ៊ុនឯកជន ដែលទទួលខុសត្រូវមានកម្រិត តើផ្នែកណានៃប្រាក់ចំណូលប្រចាំឆ្នាំត្រូវចាត់ទុកថាជាប្រាក់ចំណូលរួមរបស់ប្តីប្រពន្ធ? គេត្រូវដឹងថាមានតែអ្នកដែលមានភាគហ៊ុនច្រើនជាងគេ ទើបមានសិទ្ធិសម្រេចអំពីផលកម្រៃរបស់ក្រុមហ៊ុនដែលនឹងត្រូវយកទៅចែកចាយក្នុងចំណោមកូនហ៊ុន ។

នៅក្នុងឧទាហរណ៍បន្ទាប់ទៀត ភាគីម្ខាងនៃសហព័ទ្ធនាំមកនូវការកើនឡើងនៃតម្លៃទ្រព្យសម្បត្តិដោយឡែកនៃគូភាគីម្ខាងទៀត ប៉ុន្តែភាគីដែលនាំមកនូវការកើនឡើងនោះហាក់ដូចជាមិនមានសិទ្ធិក្នុងការទាមទារឲ្យដាក់ផលចំណេញនោះទៅជាទ្រព្យសម្បត្តិរួមឡើយ ។

*ឧទាហរណ៍ ប្រពន្ធធ្វើការឲ្យក្រុមហ៊ុនឯកជនដែលទទួលខុសត្រូវមានកម្រិត ដែលភាគហ៊ុនខ្លះនៅក្នុងក្រុមហ៊ុននេះគឺជារបស់ប្តី ។ តើប្រពន្ធមានសិទ្ធិទទួលបានការកើនឡើងនៃតម្លៃភាគហ៊ុនដែរឬទេ?*

*ប្រាក់បៀវត្សរ៍របស់ប្រពន្ធត្រូវបានចាត់ទុកជាទ្រព្យសម្បត្តិប្តីប្រពន្ធ ប៉ុន្តែការកើនឡើងនៃតម្លៃហ៊ុនរបស់ក្រុមហ៊ុន គឺជាទ្រព្យសម្បត្តិដោយឡែករបស់ប្តី ។*

អ្វីទាំងអស់នេះអាចបណ្តាលឲ្យមានភាពមិនយុត្តិធម៌ ឧទាហរណ៍ ក្នុងករណីដែលប្រពន្ធខិតខំប្រឹងប្រែងធ្វើការងារនៅក្នុងក្រុមហ៊ុន ប៉ុន្តែទទួលបានប្រាក់បៀវត្សរ៍តិច ឬគ្មានសោះ ទោះបីជាខ្លួនបានជួយឲ្យមានការកើនឡើងនៃប្រាក់ចំណូលរបស់ក្រុមហ៊ុនក្តី ។ ភាពអយុត្តិធម៌បែបនេះអាចបន្ធូរបន្ថយបានដោយការស្នើសុំរបស់ភាគីខាងប្រពន្ធឲ្យអនុវត្តមាត្រា ៩៨០ នៃក្រមរដ្ឋប្បវេណី ដែលអនុញ្ញាតឲ្យតុលាការមិនចាំបាច់ត្រូវតែបែងចែកទ្រព្យសម្បត្តិប្តីប្រពន្ធជាពីរចំណែកនោះទេ ។ ករណីលើកលែងនេះនឹងបកស្រាយនៅផ្នែក ៣.៣ ដូចខាងក្រោម ។

## ២.៣.២ ការចាត់ចែងទ្រព្យសម្បត្តិជាឯកតោភាគី

ចំណុចសំខាន់បំផុតនៃការកំណត់ទ្រព្យសម្បត្តិប្តីប្រពន្ធ គឺក្នុងគោលបំណងការពារកុំមានការអនុវត្តសកម្មភាពឯកតោភាគីរបស់សហព័ទ្ធតែម្ខាង ។ ច្បាប់ចែងថាទ្រព្យសម្បត្តិប្តីប្រពន្ធមិនអាចយកទៅលក់ ឬធ្វើការចាត់ចែងបានឡើយ បើគ្មានការយល់ព្រមពីប្តីប្រពន្ធទាំងសងខាងនោះទេ[១៥] ។ ប៉ុន្តែបទបញ្ញត្តិស្តីពីការហាមប្រាមនេះមានន័យទូលំទូលាយ ដែលការបកស្រាយហួតចត់ពេកអាចធ្វើឲ្យជីវិតប្រចាំថ្ងៃ មានការលំបាកដោយមិនសមហេតុផល ។

*ឧទាហរណ៍ មានប្រពន្ធម្នាក់លក់ម៉ូតូម៉ាក Scoopy តម្លៃ ៣២៥ ដុល្លារសហរដ្ឋអាមេរិក តាមរយៈបណ្តាញអ៊ីនធឺណិត ។*

---

[15] *ដូចខាងលើ មាត្រា ៩៧៦ (១) ។*

*ម៉ូតូ Scoopy គឺជាទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ ។ នៅពេលដែរបុរសជាប្ដីដឹងឮពីការលក់នេះ នៅថ្ងៃបន្ទាប់ គាត់ជំទាស់ និងទៅតុលាការ ដើម្បីឲ្យលុបចោលនូវកិច្ចសន្យាជាមួយអ្នកទិញ ។*

*តើការយល់ព្រមពីសំណាក់ប្ដីត្រូវការដែរឬទេសម្រាប់ការលក់អចលនទ្រព្យសាមញ្ញបែបនេះ? បើយោងទៅតាមហេតុផលទូទៅ ចម្លើយគឺទេ ។ នៅក្នុងស្ថានភាពបែបនេះ អ្នកទិញមិនត្រូវបានរំពឹងសួរអ្នកលក់ថាតើរៀបការហើយឬនៅ ប្រសិនជារៀបការហើយ តើប្ដីយល់ព្រមចំពោះការលក់នេះដែរឬទេ ។ បើមិនដូច្នោះទេ ការលក់ដូរក្នុងជីវិតប្រចាំថ្ងៃអាចនឹងមានភាពលំបាក និងភាពមិនប្រាកដប្រជាខាងគតិយុត្តិច្រើនហួសប្រមាណ ។*

> *ឧទាហរណ៍ដដែល ប្រពន្ធម្នាក់លក់ម៉ូតូម៉ាក Scoopy តម្លៃ ៣២៥ ដុល្លារសហរដ្ឋអាមេរិកតាមរយៈបណ្ដាញអ៊ីនធឺណិត ។*
>
> *ម៉ូតូស្កុតទ័រគឺជាទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ ។ នៅថ្ងៃបន្ទាប់ ប្រពន្ធស្ដាយក្រោយចំពោះការលក់នេះ និងបានឲ្យប្ដីរបស់ខ្លួនទៅតុលាការ ដើម្បីរំលាយកិច្ចសន្យាលក់ជាមួយអ្នកទិញ ។*

*ការបកស្រាយសមហេតុផលនៃមាត្រាអាចបង្ការកុំឲ្យមានភាពមិនប្រាកដប្រជាខាងគតិយុត្តិ និងការរំលោភបំពាន ដែលនាំឲ្យការធ្វើជំនួញប្រចាំថ្ងៃមានការលំបាក ។*

*ប៉ុន្តែ ពេលខ្លះ ការការពារភាគីសហព័ទ្ធ ដែលមិនបានផ្ដល់ការយល់ព្រម ជាពិសេសសម្រាប់កិច្ចសន្យាលក់អចលនទ្រព្យ ពិតជាសមរម្យ ។*

> *ឧទាហរណ៍ ប្ដីបានបាត់បង់ដីមួយប្លង់ដែលជាផ្នែកមួយនៃទ្រព្យសម្បត្តិរួមក្នុងល្បែងស៊ីសង ។*
>
> *ភាគីជាប្រពន្ធមានសិទ្ធិលើដីនោះដែរ យោងទៅតាមប្រព័ន្ធទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធដែលកំណត់ដោយច្បាប់ ទោះបីជាដីនោះចុះបញ្ជីដោយមានឈ្មោះប្ដីតែមួយក៏ដោយ ។ មាត្រា ៩៧៦ នៃកថាខណ្ឌទី១ ក្នុងក្រមរដ្ឋប្បវេណីផ្ដល់សិទ្ធិការពារទៅដល់ភាគីប្រពន្ធ ។*

*នៅក្នុងករណីនេះ ក្រមរដ្ឋប្បវេណីគួរតែការពារភាគីប្រពន្ធ ដោយអនុញ្ញាតឲ្យប្រពន្ធអាចទាមទារឲ្យលុបចោលនូវការចាត់ចែងនេះបាន ។ សហព័ទ្ធត្រូវតែធ្វើការទាមទារទៅតុលាការ ក្នុងអំឡុង*

ពេល ២ ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែង បើទ្រព្យសម្បត្តិរួមដែលត្រូវបានចាត់ចែងនោះជា អចលនវត្ថុ និងនៅក្នុងអំឡុងពេល ១ ឆ្នាំ គិតចាប់ពីពេលដែលបានដឹងអំពីការចាត់ចែងនោះ បើជាទ្រព្យសម្បត្តិរួមដែលត្រូវបានបែកចែកនោះជាចលនវត្ថុ[១៦] ។

ក្រមរដ្ឋប្បវេណីមិនបានចែងឲ្យច្បាស់លាស់ថាតើប្រាក់កើតចេញពីអ៊ីប៉ូតែង ការជួល ការធ្វើសម្បទាន និងសិទ្ធិដទៃទៀត ដែលជាទ្រព្យសម្បត្តិរួមគួរចាត់ទុកជាការលក់ជាឯកតោភាគី និងការចាត់ចែងផ្សេងៗដែលត្រូវបានច្បាប់ហាមឃាត់ឬយ៉ាងណា ។

*ឧទាហរណ៍ ប្ដីយល់ព្រមជួលផ្ទះល្វែងក្នុងតម្លៃ ៨០០ ដុល្លារសហរដ្ឋអាមេរិកក្នុងមួយខែ ។ ផ្ទះល្វែងនេះគឺជាផ្នែកមួយនៃទ្រព្យសម្បត្តិរួម ។*

ជំនួញប្រភេទនេះគួរតែចាត់ទុកជាការបែកចែកដោយឯកតោភាគី ដែលតម្រូវឲ្យមានការយល់ព្រមពីសហព័ទ្ធទាំងសងខាង ។

មាត្រា ៩៧៦ នៃក្រមរដ្ឋប្បវេណី គួរតែបកស្រាយក្នុងរបៀបមួយ ដែលអាចការពារសហព័ទ្ធទាំងពីរពីការផ្ទេរកម្មសិទ្ធិនៃ (ផ្នែកខ្លះនៃ) អចលនវត្ថុដែលជាទ្រព្យសម្បត្តិជារួមប្ដីប្រពន្ធ ។

### ២.២.៣. ការការពារចំពោះទីសំណាក់ដែលជាទ្រព្យសម្បត្តិដោយឡែក

ក្រមរដ្ឋប្បវេណីផ្ដល់នូវការការពារបន្ថែមលើសិទ្ធិប្រើប្រាស់ទីសំណាក់ ដែលជាទ្រព្យសម្បត្តិដោយឡែក ។ ថ្វីបើទីសំណាក់ជាទ្រព្យសម្បត្តិដោយឡែកក៏ដោយ សហព័ទ្ធដែលជាកម្មសិទ្ធិករត្រូវតែទទួលការអនុញ្ញាតពីសហព័ទ្ធម្ខាងទៀតដែលមិនមែនជាកម្មសិទ្ធិករ ក្នុងករណីលក់ ឬ ចាត់ចែងអចលនវត្ថុ ។ ប្រសិនបើសហព័ទ្ធមិនមែនជាកម្មសិទ្ធិករពុំផ្ដល់ការអនុញ្ញាត នោះសហព័ទ្ធម្ខាងនេះក៏អាចបន្តអាស្រ័យនៅទីសំណាក់នោះបានដែរ[១៧] ។

ដោយសារតែមូលហេតុនេះ តតិយជននៃកិច្ចសន្យាលក់ ជួល ឬ អ៊ីប៉ូតែក មានកាតព្វកិច្ចពិនិត្យមើលថាតើអ្នកលក់ អ្នកជួល រៀបអាពាហ៍ពិពាហ៍ហើយឬនៅ ប្រសិនបើរៀបអាពាហ៍ពិពាហ៍ហើយ តតិយជនត្រូវតែទទួលការអនុញ្ញាតពីសហព័ទ្ធទាំងពីរដើម្បីធ្វើជំនួញជាមួយ ។

[១៦] ដូចខាងលើ មាត្រា ៩៧៦ កថាខណ្ឌ៣ ។

[១៧] *Id.* មាត្រា ៩៧៧ ។

ក្នុងករណីសហព័ទ្ធទាំងពីរធ្វើការព្រមព្រៀងមុនពេលរៀបអាពាហ៍ពិពាហ៍ ដែលចែងថាទ្រព្យសម្បត្តិគួរតែចាត់ចែងខុសពីប្រព័ន្ធទ្រព្យសម្បត្តិដែលកំណត់ដោយច្បាប់ បើមិនបានចុះបញ្ជីទេ មិនអាចយកកិច្ចសន្យានោះមកតតាំងជាមួយនឹងតតិយជនបានឡើយ[១៨] ។

*ឧទាហរណ៍ ប្តីបានទទួលកម្មសិទ្ធិលើដីក្នុងភូមិមួយ មុនពេលរៀបអាពាហ៍ពិពាហ៍ ហើយដីនោះចុះបញ្ជីដោយឈ្មោះរបស់ប្តី ។ តតិយជនទិញដីនេះពីប្តី ដោយមិនមានការអនុញ្ញាតពីភាគីប្រពន្ធ ។ ក្រោយមក ប្រពន្ធជំទាស់ដោយផ្អែកលើមូលហេតុថា នៅក្នុងកិច្ចព្រមព្រៀងមុនពេលរៀបអាពាហ៍ពិពាហ៍ កំណត់ថាអចលនទ្រព្យនេះជាទ្រព្យសម្បត្តិរួម ។ កិច្ចព្រមព្រៀងនេះមិនបានចុះបញ្ជីនោះទេ ។*

ប្រពន្ធមិនអាចលុបចោលកិច្ចសន្យា ដោយគ្រាន់តែផ្អែកលើមូលហេតុថាមិនបានផ្តល់ការយល់ព្រមចំពោះការលក់ ទោះបីខ្លួនជាម្ចាស់នៃទ្រព្យសម្បត្តិរួមនេះក៏ដោយ ។ ប៉ុន្តែ ភាគីជាប្រពន្ធ អាចទាមទារយកប្រាក់ចំណេញពាក់កណ្តាលពីការលក់ទ្រព្យសម្បត្តិរួមនេះ ។

## ២.៤ ការចំណាយក្នុងផ្ទះសម្បែង

ក្រមរដ្ឋប្បវេណីក៏កំណត់អំពីរបៀបបែងចែកការចំណាយក្នុងផ្ទះសម្បែងដែរ ។ សហព័ទ្ធទាំងសងខាងមានចំណែកលើបន្ទុកនៃការចំណាយក្នុងផ្ទះសម្បែង ដោយពិចារណាទៅលើទ្រព្យសម្បត្តិ ប្រាក់ចំណូល និងស្ថានភាពផ្សេងៗទៀត[១៩] ។ ទោះបីជាយ៉ាងណា មាត្រានេះនៅពុំទាន់មានលក្ខណៈច្បាស់លាស់នៅឡើយ ។ ការចំណាយក្នុងផ្ទះសម្បែងអាចសន្មតថាត្រូវគិតគូដោយប្រាក់ចំណូលរួមមុនសិន ។ ក៏ប៉ុន្តែតើប្តីប្រពន្ធគួរធ្វើយ៉ាងណា ប្រសិនបើប្រាក់ចំណូលបានចំណាយអស់? តើការចំណាយនេះគួរតែទូទាត់ជាមួយនឹងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធបន្ទាប់មកទៀតឬ? ក្នុងករណីដែលនៅតែមិនទាន់គ្រប់គ្រាន់ តើអាចទូទាត់ជាមួយប្រាក់ចំណូលពីទ្រព្យសម្បត្តិដោយឡែកបានឬទេ[២០] ?

## ២.៥ អំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈដោយសហព័ទ្ធ

[១៨] *Id.* មាត្រា ៩៧០ (២) ។

[១៩] ដូចខាងលើ មាត្រា ៩៧១ ។

[២០] ដូចដែលបានពិភាក្សាខាងលើ ប្រាក់ចំណេញទទួលបានពីទ្រព្យសម្បត្តិដោយឡែកមិនអាចចាត់ទុកជាប្រាក់ចំណូលដោយឡែកនោះទេ ។

បញ្ហាទាក់ទិននឹងវិសាលភាពរបស់អំពើហិង្សាក្នុងគ្រួសារនៅប្រទេសកម្ពុជាមានទំហំធំពេក ដូច្នេះការពិភាក្សាអំពីបញ្ហាទាំងអស់នេះឲ្យបានស៊ីជម្រៅក្នុងអត្ថបទនេះមិនអាចធ្វើទៅបានឡើយ ហើយអំពើហិង្សាជាប្រធានបទនៃគម្រោងស្រាវជ្រាវ និងមានការបោះពុម្ពផ្សាយជាច្រើនមកហើយ ។ ប៉ុន្តែបញ្ហាពីរទាក់ទិនអំពើហិង្សានឹងលើកមកពិភាក្សា ។ ទីមួយ ការស្រាវជ្រាវបង្ហាញថាស្ត្រីមិនចាកចេញពីអាពាហ៍ពិពាហ៍ដែលមានអំពើហិង្សា ដោយសារតែមូលហេតុសេដ្ឋកិច្ច ដូចជា«ប្តីរកប្រាក់ចំណូលបានច្រើនជាង...ជាពិសេសនៅតំបន់ជនបទ[២១] ។» នេះបង្ហាញឲ្យឃើញថាជាមួយនឹងការកើនឡើងនៃវណ្ណៈកណ្តាលរួមទាំងចំនួនស្ត្រីដែលឯករាជ្យខាងផ្នែកហិរញ្ញវត្ថុ អត្រាលែងលះនៅកម្ពុជាអាចរំពឹងថានឹងកើនឡើងដែរ ។

ទីពីរ មានការការពារផ្នែកច្បាប់ប្រឆាំងនឹងការរំលោភសេពសន្ថវៈដោយសហព័ទ្ធ ដែលជាបញ្ហាកំពុងកើនឡើងជាញឹកញាប់នៅកម្ពុជា ។ ការស្ទង់មតិមួយដែលបានធ្វើឡើងក្នុងឆ្នាំ២០០៥ បង្ហាញថា ១៤ ភាគរយនៃអ្នកឆ្លើយតបទាំងអស់ ស្គាល់ស្ត្រីយ៉ាងតិចម្នាក់ដែលធ្លាប់ត្រូវប្តីបង្ខំឲ្យរួមភេទដុយនឹងឆន្ទៈរបស់ខ្លួន[២២] ។ នៅប្រទេសកម្ពុជា មានការភាន់ច្រឡំថាការរំលោភសេពសន្ថវៈដោយសហព័ទ្ធមិនមែនជាបទល្មើស ។ យោងទៅតាមការស្ទង់មតិឆ្នាំ២០០៥ បង្ហាញថា ៤៥ ភាគរយនៃប្រជាជនកម្ពុជា[២៣] ទាំងអស់យល់ថាប្តីមានសិទ្ធិបង្ខំឲ្យប្រពន្ធរួមភេទជាមួយខ្លួន ។ ទោះបីជាច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះចែងជាទូទៅទាក់ទងនឹងការរំលោភបំពានខាង ផ្លូវភេទតែមិនបាននិយាយអំពីការរំលោភសេពសន្ថវៈដោយសហព័ទ្ធឲ្យបានច្បាស់លាស់ក៏ដោយច្បាប់
នេះគួរតែមានចែងពីការរំលោភសេពសន្ថវៈដោយសហព័ទ្ធ[២៤] ។ យោងតាមក្រមព្រហ្មទណ្ឌ អំពើ

---

[២១] Katherine Brickell, Baurenksmey Prak និង Bunnak Poch *សរសេររបាយការណ៍ស្រាវជ្រាវដែលមានចំណងជើងថា Domestic Violence Law: The Gap between Legislation and Practice in Cambodia and What Can Be Done About It (២០១៤), ទំព័រទី១៨, មាននៅលើគេហទំព័រ* http://www.katherine brickell.com / katherinebrickell/wp-content/uploads/2014/01/DV-Law-Prelim-Report-2014.pdf ។

[២២] Catherine Cecil et al., *សរសេររបាយការណ៍ដែលមានចំណងជើងថា* Violence Against Women- A Baseline Survey *(២០០៥), ទំព័រទី៥៧, មាននៅលើគេហទំព័រ* http://www.unwomen-eseasia.org/ projects/Cedaw/docs/2006/Baseline%20VAW-2005engl.pdf

[២៣] *ដូចខាងលើ ។*

[២៤] *សូមមើលរបាយការណ៍របស់* The Cambodian Committee of Women (Cambo) *ដែលមានចំណងជើងថា Violence Against Women: How Cambodia Laws Discriminate Against Women (វិច្ឆិកា ២០០៧),*

រំលោភសេពសន្ថវៈដោយសហព័ទ្ធឲ្យជាប់ពន្ធនាគារពី៥ ឆ្នាំទៅ ១០ ឆ្នាំ[២៥] ។ ប៉ុន្តែ មន្ត្រីជាច្រើននៅក្នុងវិស័យយុត្តិធម៌ខ្វះការយល់ដឹងអំពីបញ្ហានេះ និងអាក់ខានមិនបានកាត់ទោសការរំលោភសេពសន្ថវៈដោយសហព័ទ្ធ ។ ការសិក្សាក្នុងតំបន់មួយដែលធ្វើឡើងដោយអង្គការសហប្រជាជាតិនាពេលថ្មីៗនេះរកឃើញថា បុរសជាច្រើន (ពី៧២ ភាគរយ ដល់ ៩៧ ភាគរយ) ដែលបានប្រព្រឹត្តិបទរំលោភសេពសន្ថវៈមិនត្រូវបានផ្តន្ទាទោស ជាពិសេសគឺការរំលោភសេពសន្ថវៈដោយសហព័ទ្ធ[២៦] ។

## ២.៦. ទ្វេពន្ធភាព និងការចុះចោលលំនៅសន្ធាស

ការប្រព្រឹត្តបទទ្វេពន្ធភាព និងការចុះចោលលំនៅសន្ធាសដោយភាគីបុរសកើតឡើងជាញឹកញាប់នៅប្រទេសកម្ពុជា ។ បញ្ហានេះបណ្តាមកពីអាត្រាអតុល្យភាពនៃកម្រិតយេនឌ័រ ដោយសារតែអត្រាមរណភាពបុរសមានកម្រិតខ្ពស់ក្នុងសម័យខ្មែរក្រហម[២៧] និងកត្តាមួយទៀតគឺអំណាចមិនស្មើគ្នារវាងបុរស និងនារី ។ ក្នុងករណីទ្វេពន្ធភាពគឺប្តីរៀបការជាមួយនារីម្នាក់ផ្សេងទៀត ដោយមិនបានលែងលះប្រពន្ធដើមជាមុនសិន ។ ក្នុងករណីចុះចោលលំនៅសន្ធាសវិញ បុរសជាប្តីចាប់ផ្តើមជីវិតថ្មីជាមួយនារីម្នាក់ផ្សេងទៀត ដោយមិនបានរៀបការជាមួយនាង ហើយនៅតែមានចំណង

---

ទំព័រទី៩, មាននៅលើគេហទំព័រ www.licadho-cambodia.org/reports/files/112CAMBOWViolenceWomenReport2007_ENG.pdf ។

[២៥] សូមមើលច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ (២០០៥), មាត្រា៧, មាននៅលើគេហទំព័រ www.wcwonline.org/pdf/lawcompilation/Cambodia_dv_victims2005.pdf

និងក្រមព្រហ្មទណ្ឌកម្ពុជា (២០០៩), មាត្រា ២៣៩, មាននៅលើគេហទំព័រ www.unodc.org/res/cld/document/ khm/criminal_code_of_the_kingdom_of_cambodia_html/Cambodia_Criminal-Code-of-the-Kingdomof-Cambodia-30-Nov-2009-Eng.pdf ។

[២៦] Emma Fulu et al. សរសេររបាយការណ៍មួយដែលមានចំណងជើងថា *Why Do Some Men Use Violence Against Women and How Can We Prevent It? Quantitative Findings from the United Nations Multi-country Study on Men and Violence in Asia and the Pacific* (២០១៣), មាននៅលើគេហទំព័រ http://unwomen- asiapacific.org/docs/WhyDoSomeMenUseViolenceAgainst Women_P4P_Report.pdf ។

[២៧] Patrick Heuveline និង Bunnak Poch សរសេរអត្ថបទមួយដែលមានចំណងជើងថា *Do Marriages Forget Their Past? Marital Stability in Past-Khmer Rouge Cambodia*, 43:I DEMOGRAPHY 99 (កុម្ភៈ ២០០៦), មាននៅលើគេហទំព័រ www.ncbi.nlm.nih.gov/pmc/articles/PMC3930764/ ។

អាពាហ៍ពិពាហ៍ជាមួយប្រពន្ធដើមរបស់ខ្លួន ។ ទ្វេពន្ធភាពគឺជាអំពើឧក្រិដ្ឋដែលត្រូវបានហាមឃាត់[២៨] ប៉ុន្តែការហាមឃាត់នេះមានប្រសិទ្ធិភាពតែចំពោះអាពាហ៍ពិពាហ៍បានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ ខណៈដែលអាពាហ៍ពិពាហ៍ជាច្រើន ដូចដែលបានពិភាក្សាខាងលើមិនបានចុះបញ្ជី ។ ការចុះចោលលំនៅសន្ធាសមិនមែនជាបទល្មើសឧក្រិដ្ឋនោះទេ ។ ទ្វេពន្ធភាព និងការចុះចោលលំនៅសន្ធាសគឺជាហេតុផលដែលប្រពន្ធអាចយកមកសម្អាង ដើម្បីទាមទារឲ្យមានការលែងលះ និងសិទ្ធិក្នុងអាពាហ៍ពិពាហ៍[២៩] ។

## ៣. ការលែងលះ

### ៣.១. សេចក្ដីផ្ដើម

ពុំមានស្ថិតិថ្មីៗដែលអាចទុកចិត្តបានស្ដីអំពីអត្រានៃការលែងលះនៅប្រទេសកម្ពុជាទេ ។ ផ្អែកលើជំរឿនប្រជាជនឆ្នាំ២០០៨ ករណីចុះចោលលំនៅសន្ធាស (០,១ ភាគរយ) និងការលែងលះ (២ ភាគរយ) មានតិច[៣០] ។ ដូចដែលបានចង្អុលបង្ហាញដោយ ព្រីកខែល (Brickell) ភាពចុះសម្រុងគ្នា និងការផ្សះផ្សាមានសារសំខាន់ណាស់ក្នុងវប្បធម៌ខ្មែរ[៣១] ។ នេះក៏បានបង្ហាញក្នុងគោលបំណងនៃច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដែលបានចែងថា "...បង្កើតយន្តការនីត្យានុកូល ដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងថែរក្សាភាពសុខដុមរមនាក្នុងគ្រួសារតាមទំនៀមទម្លាប់ និងប្រពៃណីល្អរបស់ជាតិ[៣២] ។" ដូច្នេះ ការសម្រុះសម្រួល និងផ្សះផ្សាភាពខុសគ្នាក្នុងអាពាហ៍ពិពាហ៍គឺជានិន្នាការវប្បធម៌ ។

ទោះជាដូច្នេះក្ដី អត្រាលែងលះទាបនៅក្នុងជំនឿឆ្នាំ២០០៨ មិនបានបង្ហាញពីការពិតនោះទេ ហើយអាត្រារស់នៅបែកគ្នា និងលែងលះអាចសន្មតបានថាខ្ពស់ជាងនេះ ។ ការបកស្រាយខុសនេះអាច

---

[២៨] ការហាមឃាត់មិនឲ្យមានទ្វេពន្ធភាពក្នុងមាត្រា ៩៤៩ នៃក្រមរដ្ឋប្បវេណី និងត្រូវដាក់ទណ្ឌកម្មពិន័យជាទឹកប្រាក់ដល់ ២ លានរៀល យោងទៅតាមមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌកម្ពុជា ។

[២៩] ក្រមរដ្ឋប្បវេណី មាត្រា ៩៧៨ (១) (ក) ។ ទ្វេពន្ធភាពអាចចាត់ទុកបានជាការប្រព្រឹត្តអំពើផិត ។

[៣០] វិទ្យាស្ថានជាតិស្ថិតិ, ជំរឿនប្រជាជនកម្ពុជាឆ្នាំ ២០០៨, មាននៅលើគេហទំព័រ www.nis.gov.kh/nis/census2008/Census.pdf ។

[៣១] Katherine Brickell, សរសេររបាយការណ៍មួយដែលមានចំណងជើងថា *'Plates in a Basket Will Rattle': Marital Dissolution and Home 'Unmaking' in Contemporary Cambodia*, 51 GEOFORUM 265, 265 (២០១៣) ។

[៣២] មាត្រាទី១នៃច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ។

បណ្តាមកពីភាពនៅមានកម្រិតនៃការស្គាល់មតិដែលអ្នកចូលរួមអាចជ្រើសរើសចម្លើយ ដោយពុំមានការជ្រៀតជ្រែកពីអ្នកស្រាវជ្រាវ រួមទាំងបញ្ហាមួយចំនួនទៀតដូចជា កង្វះខាតនៃទិន្នន័យត្រឹមត្រូវបញ្ជីអាត្រានុកូលដ្ឋានថ្មីបំផុត និងការលែងលះមិនស្របច្បាប់ដូចដែលបានពិភាក្សាខាងលើ ។ កាលពីឆ្នាំ ២០០៣ (Hirschman) និង (Teerawichitchainan) ប៉ាន់ប្រមាណថាអត្រាលែងលះមានចំនួន ៧ ភាគរយ[៣៣] ។ អត្រានេះទំនងជាបង្ហាញពីតួលេខពិតនៃការលែងលះក្នុងសង្គមបច្ចុប្បន្ន ពីព្រោះក្រុមប្រឹក្សាឃុំសង្កាត់រាយការណ៍ថា ការលែងលះ និងអំពើហិង្សាក្នុងគ្រួសារគឺជាប្រភេទជម្លោះដែលត្រូវដោះស្រាយច្រើនជាងគេ[៣៤] ។ ទោះជាយ៉ាងណាក្តី អត្រាលែងលះនៅតែមានកម្រិតទាបជាងនៅបស្ចិមប្រទេស ដោយសារការបាត់បង់កិត្តិយសចំពោះស្ត្រីដែលលែងលះ និងពឹងពាក់ប្តីទាំងស្រុងខាងផ្នែកសេដ្ឋកិច្ច ។ ក្រសួងកិច្ចការនារីក៏បានបញ្ជាក់ដែលថាការលែងលះគឺជាជម្រើសក្រោយបំផុត[៣៥] ។

មូលហេតុសម្រាប់ការលែងលះមានច្រើន ហើយមូលហេតុទាំងអស់នេះមានលក្ខណៈស្រដៀងគ្នានឹងវប្បធម៌របស់ប្រទេសដទៃទៀត ប៉ុន្តែអ្វីដែលគួរឲ្យកត់សម្គាល់គឺអាពាហ៍ពិពាហ៍ជាច្រើននៅប្រទេសកម្ពុជាពុំមានសុភមង្គល ដោយសារតែវិបត្តិផ្លូវចិត្តបណ្តាលមកពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជំនាន់ទីមួយ និងជំនាន់ទីពីរ រួមទាំងករណីអំពើហិង្សាក្នុងគ្រួសារច្រើន បញ្ហាល្បែងស៊ីសងការផឹកស្រា ញៀនថ្នាំ ការបុះបោលលំនៅសង្វាស និងទ្វេពន្ធភាព[៣៦] ។

ទោះបីជាមូលហេតុស្របច្បាប់សម្រាប់ការលែងលះនៅមានកម្រិតក៏ដោយ មូលហេតុទាំងអស់នេះគាក់តែងឡើងមានលក្ខណៈទូលំទូលាយ ដោយហេតុផលជាច្រើនទៀសម្រាប់ដាក់បណ្តឹងលែងលះប្រសិនបើសហព័ទ្ធសុំដាច់មគ្គសង្វាស ។ មូលហេតុនៃការលែងលះគ្នាមានដូចជាការប្រព្រឹត្តអំពើផិតការបោះបង់សហព័ទ្ធចោល ការរស់នៅបែកគ្នាអស់រយៈពេលជាង១ ឆ្នាំ និងការបែកបាក់ចំណង

---

[៣៣] Charles Hirschman និង Bussarawan Teerawichitchainan និពន្ធអត្ថបទមួយដែលមានចំណងជើងថា *Cultural and Socioeconomic Influences on Disvorce During Modernization: Southeast Asia, 1940s to 1960s*, 29:2 POPULATION & DEV.REV.215 (មិថុនា ២០០៣) ។

[៣៤] UNDP, *Pathways to Justice* (២០០៥), ទំព័រទី ១១៥ ។

[៣៥] Remarks at Legal Aid of Cambodia Workshop, *Access to Divorce for Women in Cambodia* (មិនា ១៧ ២០១០) (on file with author)

[៣៦] សូមមើល UNDP កំណត់ចំណាំលេខ ៣៤, ទំព័រទី ៧៩ ។

អាពាហ៍ពិពាហ៍[៣៧] ។ ច្បាប់នៅតែអនុញ្ញាតឲ្យតុលាការប្រើឆន្ទានុសិទ្ធិរបស់ខ្លួន ដើម្បីប្រានចោលការទាមទារលែងលះគ្នា ប្រសិនបើយល់ថាជនដែលទាមទារឲ្យលែងលះគ្នានោះ ធ្វេសប្រហែសយ៉ាងខ្លាំងក្នុងការសហប្រតិបត្តិ និងជួយសង្គ្រោះចំពោះសហព័ទ្ធម្ខាងទៀត ។ ការដាក់កម្រិតទៅលើសិទ្ធិលែងលះបង្ហាញថាតម្លៃនៃវប្បធម៌ខ្មែរភ្ជាប់នឹងចំណងអាពាហ៍ពិពាហ៍ប្រឆាំងនឹងសិទ្ធិស្វ័យសម្រេច ។ ប៉ុន្តែ ក្រមរដ្ឋប្បវេណីមានលក្ខណៈទាន់សម័យ ដោយអនុញ្ញាតឲ្យមានការដាក់ពាក្យបណ្ដឹងលែងលះរួមគ្នានិងចាំបាច់ប្រាប់ពីមូលហេតុច្បាស់លាស់ចំពោះការលែងលះ[៣៨] ។ នេះបង្ហាញឲ្យឃើញថារដ្ឋគោរពសិទ្ធិឯកជនរបស់ប្ដីប្រពន្ធ ដែលសម្រេចចិត្តលែងលះដោយមិនចាំបាច់បកស្រាយពីមូលហេតុទៅដល់រដ្ឋនោះទេ ។

## ៣.៧. នីតិវិធី

អាពាហ៍ពិពាហ៍ស្របច្បាប់គឺជាអាពាហ៍ពិពាហ៍ដែលបានចុះបញ្ជីត្រឹមត្រូវនៅទីកន្លែងចុះអត្រានុកូលដ្ឋាន ហើយអាពាហ៍ពិពាហ៍នេះអាចរំលាយបាន លុះត្រាតែមានដីកាលែងលះចេញដោយតុលាការ ។ ការដាក់ពាក្យប្ដឹងសុំលែងលះអាចដាក់ជូនទៅកាន់តុលាការផ្ទាល់ ឬទៅក្រុមប្រឹក្សាឃុំសង្កាត់ ។ ក្នុងករណីភាគីដាក់ពាក្យសុំលែងលះគ្នាទៅក្រុមប្រឹក្សាឃុំសង្កាត់ ក្រុមប្រឹក្សាឃុំសង្កាត់មានពេល ១៥ ថ្ងៃ ដើម្បីបញ្ចុះបញ្ចូលឲ្យប្ដីប្រពន្ធសះជាគ្នាវិញ ។ ប្រសិនបើការបញ្ចុះបញ្ចូលនេះមិនបានជោគជ័យ ក្រុមប្រឹក្សាឃុំសង្កាត់ត្រូវបញ្ជូនពាក្យសុំលែងលះគ្នាទៅតុលាការ[៣៩] ។

បន្ទាប់ពីទទួលបានពាក្យសុំលែងលះ តុលាការបង្គាប់ឲ្យភាគីទាំងពីរបង្ហាញមុខចំពោះតុលាការ ។ ចៅក្រមភាគច្រើននឹងព្យាយាមបញ្ចុះបញ្ចូលដើមបណ្ដឹងឲ្យដកពាក្យបណ្ដឹងលែងលះគ្នា ។ ប្រសិនបើដើមបណ្ដឹងនៅតែទាមទារយ៉ាងខ្លាំង តុលាការអាចធ្វើការចាត់ចែងជាបណ្ដោះអាសន្ន ដែលនឹងបកស្រាយនៅផ្នែក៣.៦ ខាងក្រោម ។ នៅក្នុងដំណាក់កាលនេះ តុលាការតែងតែព្យាយាមធ្វើការផ្សះផ្សាបីដង ដើម្បីមើលថាតើប្ដីប្រពន្ធអាចផ្សះផ្សាបានដែរឬទេ ។ ក្នុងករណីដើមបណ្ដឹងនៅតែទទូចចង់លែងលះ តុលាការនឹងធ្វើការវិនិច្ឆ័យលើ បណ្ដឹងលែងលះ ការបែងចែកទ្រព្យសម្បត្តិរួម

---

[៣៧] សូមមើលមាត្រា ៩៧៨ (១) នៃក្រមរដ្ឋប្បវេណី ។

[៣៨] ដូចខាងលើ មាត្រា ៩៧៩ ។

[៣៩] ដូចខាងលើ មាត្រា ៩៨២ កថាខណ្ឌ២ ។

សោធនអាហារកិច្ចរបស់សហព័ទ្ធ ការគ្រប់គ្រង ថែរក្សាកូន សិទ្ធិទៅសួរសុខទុក្ខកូន និងការផ្គត់ផ្គង់កូន ដែលចំណុចទាំងអស់នឹងបកស្រាយនៅផ្នែកបន្តបន្ទាប់ទៀត ។

នៅប្រទេសកម្ពុជា មានតែតុលាការថ្នាក់ខេត្តតែប៉ុណ្ណោះ ដូច្នេះប្រជាជននៅតាមជនបទត្រូវធ្វើដំណើរឆ្ងាយមុនមកដល់ទីរួមខេត្ត ។ ដូចបានពិភាក្សាការខាងក្រោម ដំណើរការជំនុំជម្រះរឿងក្ដីលែងលះតែងតែតម្រូវឲ្យភាគីទាំងសងខាងទៅតុលាការពីរទៅបីដង ហើយនេះគឺជាបន្ទុកដ៏ពិបាកដោះស្រាយសម្រាប់គ្រួសារក្រីក្រ ។ កង្វះខាតនៃសិទ្ធិទទួលបានការលែងលះនឹងបកស្រាយបន្ថែមទៀតនៅផ្នែក ៤.២ ខាងក្រោម ។

## ៣.៣ ការបែងចែកទ្រព្យសម្បត្តិ

ក្រមរដ្ឋប្បវេណីកំណត់ពីការបែងចែកទ្រព្យសម្បត្តិរួមក្នុងករណីលែងលះ ។ មាត្រា ៩៨០ ចែងថាទ្រព្យសម្បត្តិរួមត្រូវបែងចែក ដោយផ្អែកតាមការព្រមព្រៀងរបស់ភាគីទាំងសងខាង ។ ថ្វីបើមិនបានចែងច្បាស់លាស់ក៏ដោយ ការព្រមព្រៀងរបស់ភាគីទាំងសងខាងអាចសន្មតថារាប់បញ្ចូលទាំងកិច្ចសន្យាទាំងឡាយណាដែលសហព័ទ្ធធ្វើឡើងជាមួយគ្នាមុនពេលរៀបអាពាហ៍ពិពាហ៍ ។ ក្នុងករណីដែលប្ដីប្រពន្ធមិនអាចព្រមព្រៀងជាមួយគ្នាបាន តុលាការត្រូវតែអនុវត្តតាមប្រព័ន្ធបែងចែកទ្រព្យសម្បត្តិកំណត់ដោយច្បាប់ ។ យោងទៅតាមមាត្រា៩៧២ និង ៩៧៣ ទ្រព្យសម្បត្តិរួមត្រូវបែងចែកពាក់កណ្ដាលម្នាក់ ។ ប្រជាជនកម្ពុជាជាទូទៅដឹងអំពីសិទ្ធិទទួលបានទ្រព្យសម្បត្តិរួមពាក់កណ្ដាលម្នាក់ ហើយការយល់ដឹងជាសាធារណៈត្រូវបានលើកឡើងជាបន្ថែមនៅឆ្នាំ២០០៨ នៅពេលប្ដីម្នាក់ដែលឈប់រស់នៅជាមួយប្រពន្ធបានអារផ្ទះរបស់ពួកគេជាពីរ និងយកផ្ទះមួយចំហៀងទៅជាមួយខ្លួន[៤០] ។

ក្នុងការបែងចែកទ្រព្យសម្បត្តិរួម ចៅក្រមមានឆន្ទានុសិទ្ធិច្បាស់លាស់ក្នុងអនុវត្តខុសពីប្រព័ន្ធកំណត់ដោយច្បាប់ ទៅតាមការសំណើរបស់សហព័ទ្ធម្ខាង ៖

> បើមានករណីពិសេស និងមានការទាមទាររបស់ភាគីណាមួយក្នុងចំណោមសហព័ទ្ធទាំងពីរ តុលាការក៏អាចបែងចែកទ្រព្យសម្បត្តិរួម ដោយពិចារណាទៅលើស្ថានភាពផ្សេងៗ ដូចជាទំហំនៃការបរិច្ចាគរបស់ភាគីនីមួយៗចំពោះលទ្ធកម្មនៃ

---

[៤០] សូមមើលអត្ថបទដែលមានចំណងជើងថា *Cambodian Couple Saw House in Half in Divorce*, កាសែត *HUFFINGTON POST*, ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០០៨, មាននៅលើគេហទំព័រ www.huffingtonpost.com /2008/10/13/cambodian-couple-saw-hous_n_134098.html.

ទ្រព្យសម្បត្តិ ការថែរក្សា ឬ ការបង្កើនទ្រព្យអំឡុងពេលអាពាហ៍ពិពាហ៍កម្រិតជីវភាពរស់នៅនៅក្នុងអំឡុងពេលមានចំណងអាពាហ៍ពិពាហ៍ អាយុ ស្ថានភាព ផ្លូវចិត្ត និងផ្លូវកាយ វិជ្ជាជីវៈ ប្រាក់ចំណូល លទ្ធភាពធ្វើការងាររបស់ភាគីនីមួយៗនិងផលប្រយោជន៍ របស់កូនជាអាទិ៍[៤១] ។

ដើម្បីជាការគាំទ្រដល់ស្ត្រីទូទៅ មាត្រានេះបានបញ្ជាក់បន្ថែមថា គេហកិច្ចត្រូវចាត់ទុកថាមានតម្លៃស្មើនឹងការងារដែលធ្វើក្រៅផ្ទះ ។ តម្លៃនៃការងារមេផ្ទះក៏មានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[៤២] ។ នេះបានបង្ហាញពីភាពស្មើគ្នា ការវិឌ្ឍ និងការយល់ដឹងពីបញ្ហាយ៉េនឌ័រ ពីព្រោះស្ត្រីខ្មែរ ភាគច្រើនមិនរកបានប្រាក់ចំណូលច្រើនដូចប្តីរបស់ខ្លួននោះទេ ដោយសារតែបន្ទុកកិច្ចការងារផ្ទះដែលជាទំនៀមទម្លាប់តម្រូវឲ្យប្រពន្ធជាអ្នកទទួលរ៉ាប់រង និងកង្វះខាតការអប់រំ និងឱកាស ។

បញ្ហាច្បាស់លាស់មួយចំនួន ដែលតែងតែកើតមានឡើងក្នុងការបែងចែកទ្រព្យសម្បត្តិគឺដីនិងសិទ្ធិលើសោធននិវត្តន៍ ។

## ៣.៣.១ ដី

ដីគឺជាប្រភពធនធានដ៏មានតម្លៃសម្រាប់ប្រជាជនខ្មែរ ជាពិសេសគ្រួសារក្រីក្រ និងនៅតាមជនបទ។ ៨០ ភាគរយនៃប្រជាជនខ្មែរទាំងអស់ត្រូវបានប្រមាណថារស់នៅជនបទ[៤៣] និងប្រហែលជា ៣៦ ភាគរយនៃចំណូលសេដ្ឋកិច្ចរបស់ពួកគេមានប្រភពមកពីកសិកម្ម[៤៤] ។ កម្មសិទ្ធិដីធ្លីអាចធ្វើទៅបានតាមរយៈសុរិយោដី។ ក្នុងរបបខ្មែរក្រហម ឯកសារសុរិយោដីទាំងអស់ត្រូវបានបំផ្លាញចោល ដូច្នេះក្នុងអំឡុងពេល ១០ ឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលបានព្យាយាមខិតខំប្រឹងប្រែងចុះបញ្ជីកម្មសិទ្ធិដីធ្លីដែលមានលក្ខណៈជាប្រព័ន្ធទើបតែបង្កើតថ្មី ។

---

[៤១] ក្រមរដ្ឋប្បវេណី, មាត្រា ៩៨០ ។

[៤២] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣), មាត្រា ៣៦ ។

[៤៣] ជំរឿនប្រជាជន, កំណត់ចំណាំលេខ ៣០ ។

[៤៤] World Bank 2012 figures ចេញផ្សាយដោយ Trading Economics មាននៅលើគេហទំព័រ www.tradingeconomics.com/cambodia/agriculure-value-added-percent-of-gdp-wb.data.html ។

អង្គការក្រៅរាជរដ្ឋាភិបាល និងអង្គការអន្តរជាតិមួយចំនួនសង្កត់ធ្ងន់ទៅលើសារសំខាន់នៃកម្មសិទ្ធិដីធ្លីរួមរបស់ប្តីប្រពន្ធ ដើម្បីជាប្រយោជន៍ក្នុងកិច្ចការពារសិទ្ធិរបស់ស្ត្រី[៤៥] ។ ទោះបីជាកិច្ចការពារសិទ្ធិស្ត្រីអាចនឹងត្រូវបានអនុវត្តក៏ដោយ សហកម្មសិទ្ធិលើដីធ្លីមិនទាក់ទងនឹងកិច្ចការពារនោះទេ ប្រសិនបើផ្អែកទៅលើគោលទស្សនៈច្បាប់ ។ ដូចដែលបានពិភាក្សាខាងលើ ទ្រព្យសម្បត្តិរួមរាប់បញ្ចូលរាល់ដីធ្លីដែលសហព័ទ្ធទទួលបាននៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ លើកលែងតែដីធ្លី ដែលសហព័ទ្ធទទួលបានដោយប្រទានកម្ម សន្តតិកម្ម ឬ ទិញដោយប្រើប្រាស់ទ្រព្យសម្បត្តិដោយឡែក[៤៦] ។ មានការភាន់ច្រឡំអំពីរឿងដីធ្លីដោយយល់ថា នៅពេលដីចុះបញ្ជីដោយឈ្មោះសហព័ទ្ធតែមួយ សហព័ទ្ធមួយទៀតពុំមានកម្មសិទ្ធិទៅលើដីធ្លីនេះទេ ប៉ុន្តែការយល់បែបនេះមិនត្រឹមត្រូវនោះទេ ប្រសិនបើដីធ្លីនេះអាចកំណត់ជាទ្រព្យសម្បត្តិរួម ។ សហព័ទ្ធម្ខាងទៀតគឺជាសហកម្មសិទ្ធិស្របច្បាប់ តាមរយៈប្រព័ន្ធទ្រព្យសម្បត្តិរួមកំណត់ដោយច្បាប់ ។

*ឧទាហរណ៍ ប្តីប្រពន្ធមួយគូបានយកប្រាក់សន្សំរួមគ្នាក្នុងអំឡុងអាពាហ៍ពិពាហ៍ ទិញដីមួយប្លង់ តែប្តីគឺជាកម្មសិទ្ធិករលើដីនេះម្នាក់ឯង ។*

*ទោះបីយ៉ាងនេះក្តី ប្រពន្ធនៅតែជាសហកម្មសិទ្ធិកររួមនៃដីធ្លីនេះដែរ តាមរយៈប្រព័ន្ធទ្រព្យសម្បត្តិរួមកំណត់ដោយច្បាប់ ។*

ប៉ុន្តែ មានរឿងអ្វីកើតឡើងប្រសិនបើស្ថានភាពនេះបញ្ច្រាសវិញ? ឧទាហរណ៍ ប្តីប្រពន្ធមានដីមួយប្លង់ ហើយប្រពន្ធទទួលបានដីនេះដោយសន្តតិកម្ម តែកម្មសិទ្ធិគឺជាឈ្មោះរបស់ប្តីប្រពន្ធទាំងពីរ ។ ស្របទៅតាមប្រព័ន្ធទ្រព្យសម្បត្តិរួមកំណត់ដោយច្បាប់ ដីមួយប្លង់នេះគួរចុះបញ្ជីដោយឈ្មោះប្រពន្ធតែម្នាក់គត់ ។ ក៏ប៉ុន្តែ ឥឡូវនេះ ភាគីទាំងសងខាងបានអនុវត្តខុសពីប្រព័ន្ធកំណត់ដោយច្បាប់ ។ សំណួរចោទសួរថាតើប្តីគួរតែចាត់ទុកជាម្ចាស់នៃអចលនទ្រព្យនេះដែរឬទេ? ប្រសិនបើជាអ៊ីចឹងមែន តើប្រពន្ធអាចទាមទារការទទួលលាភដោយវិសមធម៌របស់ប្តីបានដែរទេ?[៤៧] តើប្តីអាចថ្លែង

---

[៤៥] ឧទាហរណ៍ ការអនុវត្តនេះបានបញ្ជាក់នៅក្នុងការគ្រប់គ្រងដី និងការចុះបញ្ជីរបស់ធនាគារពិភពលោក (Land Management and Registration of the World Bank) មាននៅលើគេហទំព័រ web.worldbank.org/WBSITE/EXTERNAL/COUNTRIES/EASTASIAPACIFICEXT/CAMBODIAEXTN/O,,contentMDK:21434075~menuPK:293874~page PK:2865066~piPK:2865079~theSitePK:293856,00.html ។

[៤៦] ក្រមរដ្ឋប្បវេណី មាត្រា ៩៧២ និង មាត្រា ៩៧៣ ។

[៤៧] ដូចខាងលើ, មាត្រា ៧៣៦ ។

ថាការ ចុះបញ្ជីរួមនៅសុរិយោដីគឺជាការយល់ព្រមអនុវត្តន៍ខុសពីប្រព័ន្ធទ្រព្យសម្បត្តិរួមកំណត់ដោយច្បាប់[៤៨]? គ្មានចម្លើយច្បាស់លាស់សម្រាប់ឆ្លើយតបនឹងសំណួរចោទសួរទាំងអស់នេះទេ ។

ជាគោលការណ៍ កម្មសិទ្ធិដីទទួលបានក្នុងអំឡុងពេលអាពាហ៍ពិពាហ៍នឹងត្រូវបានគ្រប់គ្រងដោយសហព័ទ្ធទាំងពីរ លើកលែងតែគេទទួលបានដីនេះដោយប្រទានកម្ម សន្តតិកម្ម ឬ សហព័ទ្ធម្នាងទិញដោយទ្រព្យសម្បត្តិផ្ទាល់សម្បត្តិផ្ទាល់ខ្លួន ។ បន្ទាប់ពីការលែងលះស្របច្បាប់ ប្តីប្រពន្ធអាចសម្រេចចិត្តបានថានរណាគឺជាកម្មសិទ្ធិករនៃដីនោះ ។ ក្នុងករណីដែលពួកគេមិនអាចធ្វើការសម្រេចចិត្តបាន តុលាការអាចចេញមុនដោះស្រាយតាមសំណូមពររបស់ប្តីប្រពន្ធ ។ តុលាការអាចបង្គាប់ឲ្យប្តីប្រពន្ធលក់ដី និងចែកប្រាក់ចំណេញជាមួយគ្នា ឬ ប្រគល់ដីទៅឲ្យសហព័ទ្ធម្នាង កំណត់ដោយកាតព្វកិច្ចបង់ពាក់កណ្តាលនៃតម្លៃទ្រព្យសម្បត្តិរួមទៅឲ្យសហព័ទ្ធមួយទៀត ។ ពុំដូច្នោះទេ ដីនោះអាចពុំចែក ហើយមានកម្មសិទ្ធិករពីរនាក់ ។ សេចក្តីវិនិច្ឆ័យរបស់តុលាការអាចប្រើ ដើម្បីកែប្រែការចុះបញ្ជីកម្មសិទ្ធិនៅសុរិយោដី ។

## ៣.២.២ សិទ្ធិលើសោធននិវត្តន៍

ក្រមរដ្ឋប្បវេណីមិនបានចែងច្បាស់លាស់ទេថា តើសិទ្ធិលើសោធននិវត្តន៍គឺជាផ្នែកមួយនៃទ្រព្យសម្បត្តិរួមដែរឬទេ ។ សិទ្ធិលើសោធននិវត្តន៍អាចរាប់បញ្ចូលសិទ្ធិរបស់អ្នករដ្ឋការ ឬ និយោជិតឯទៀត ដូចជា ការទាមទារមូលនិធិដែលបម្រុងទុកនាពេលអនាគតពីនិយោជក ។ សិទ្ធិលើសោធននិវត្តន៍កើតឡើងក្នុងអំឡុងអាពាហ៍ពិពាហ៍គួរតែចាត់ទុកថាជាទ្រព្យសម្បត្តិរួម និងបែកចែកស្មើគ្នា ។ តែរបៀបនៃការបែងចែកនេះយ៉ាងម៉េចមិនទាន់ច្បាស់លាស់នៅឡើយ ។ អនុលោមទៅតាមបទបញ្ញាសោធននិវត្តន៍មានតែនិយោជិតទេដែលអាចទាមទារចំនួនមូលនិធិសោធននិវត្តន៍បាន ។ សហព័ទ្ធទំនងជាអាចទាមទារសិទ្ធិរបស់ខ្លួនបាន លុះត្រាតែសហព័ទ្ធម្នាងទៀតជានិយោកជិតទទួលបានសិទ្ធិលើមូលនិធិសោធននិវត្តន៍ ។ បញ្ហានេះមានសារសំខាន់ចំពោះប្រពន្ធ ពីព្រោះប្តីអាចមានសិទ្ធលើមូលនិធិសោធននិវត្តន៍ ហើយប្រពន្ធមិនសក្តិសមទទួលទ្រព្យសម្បត្តិតិចជាងប្តីបន្ទាប់ពីលែងលះគ្នា ដោយសារតែប្រាក់ចំណូលទាបរបស់ប្រពន្ធ និងទំនៀមទម្លាប់ប្រពៃណី ដែលតម្រូវឲ្យស្ត្រីត្រូវតែធ្វើកិច្ចការផ្ទះ ។

## ៣.៤ អាហារកិច្ច

[៤៨] ដូចខាងលើ, មាត្រា ៩៦៩ ។

ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មិនបានផ្តល់មូលដ្ឋានគតិយុត្តិសម្រាប់បទបញ្ញត្តិអាហារកិច្ចដល់សហព័ទ្ធក្រោយពេលដែលលែងលះគ្នាដាច់ស្រឡះនោះទេ ។ តែក្រមរដ្ឋប្បវេណីមានចែងអំពីកាតព្វកិច្ចផ្តល់អាហារកិច្ចទៅដល់ញាតិដែលរស់នៅជាមួយគ្នា ញាតិលោហិតខ្សែផ្ទាល់ និងបងប្អូនបង្កើត[៤៩] ។ មូលហេតុនៃការខកខានមិនបានចែងអំពីចំណុចគឺមិនទាន់ច្បាស់លាស់នៅឡើយ ។ ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីបានដោះស្រាយបញ្ហានេះ ដោយបានចែងថាមាត្រា៧៦ និងមាត្រា៧៧ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ទាក់ទិននឹងអាហារកិច្ចនៅតែមានសុពលភាព[៥០] ។ ផ្នែកមួយនៃមាត្រា ៧៦ ចែងថា «ក្នុងករណីលែងលះគ្នា ភាគីដែលគ្មានកំហុស ហើយខ្វះខាត អាចស្នើសុំអាហារកិច្ចពីភាគីម្ខាងទៀតបាន ។»

ទាក់ទិននឹងបញ្ហាវិសមភាពយេនឌ័រនៅកម្ពុជា វាជារឿងគួរឲ្យសោកស្តាយមួយដែលសហព័ទ្ធអាចទាមទារអាហារកិច្ចពីសហព័ទ្ធម្ខាងទៀតបាន លុះត្រាតែខ្លួនពុំមានកំហុស ។ បញ្ហាគឺស្ថិតនៅត្រង់ចំណុចថា ប្រពន្ធដែលរួចផុតពីអាពាហ៍ពិពាហ៍ហិង្សា អាចត្រូវបានចាត់ទុកថាជាកំហុសរបស់ពួកគេ ខទាហរណ៍ ៧៥ ភាគរយនៃប្រជាជនខ្មែរទាំងអស់យល់ថាប្រពន្ធមិនគួរប្រាប់អ្នកដទៃអំពីអំពើហិង្សាក្នុងគ្រួសាររបស់ខ្លួនទេ ដើម្បីកុំមានការបែកបាក់ក្នុងគ្រួសារ[៥១] ។

ទោះបីជាតុលាការផ្តល់សិទ្ធិទទួលបានអាហារកិច្ចទៅដល់សហព័ទ្ធក៏ដោយ ការអនុវត្តមានការពិបាក ដោយសារតែភាពអន់ខ្សោយនៃនីតិរដ្ឋនៅប្រទេសកម្ពុជា ។ ក្នុងករណីទ្រព្យសម្បត្តិ រួមជាដីធ្លីសហព័ទ្ធគួរតែស្នើសុំតុលាការចែករំលែកដីធ្លី ដែលជាទ្រព្យសម្បត្តិរួមនេះច្រើនជាពាក់កណ្តាលជំនួសឲ្យអាហារកិច្ចដែលត្រូវផ្តល់ឲ្យទៅសហព័ទ្ធម្ខាងទៀត ។ ដូចដែលបានពិភាក្សាពីខាងដើមមាត្រា ៩៨០ កថាខណ្ឌ ២ នៃក្រមរដ្ឋប្បវេណីអនុញ្ញាតឲ្យសហព័ទ្ធណាម្ខាងធ្វើការទាមទារទៅតុលាការឲ្យផ្តល់ចំណែកនៃទ្រព្យសម្បត្តិរួមច្រើនជាងពាក់កណ្តាល ដោយផ្អែកលើប្រាក់ចំណូល និងសមត្ថភាពរកចំណូលរបស់សហព័ទ្ធទាំងពីរ ។ ខទាហរណ៍ យោងទៅតាមគោលការណ៍នៃមាត្រានេះ ប្រពន្ធអាចទាមទារជា

---

[៤៩] ដូចខាងលើ មាត្រា ១១៨០ ។

[៥០] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី (២០១១), មាត្រា ៧៨ មាននៅលើគេហទំព័រ www.cambodiainvestment.gov.kh/content/uploads/2012/03/Law-on-Implementation-of-CC_Eng_FINAL_110531.pdf ។

[៥១] The Gap Between Legislation and Practice in Cambodia, កំណត់ចំណាំលេខ ២១, ទំព័រទី៤០ ។

កម្មសិទ្ធិករនៃទ្រព្យសម្បត្តិរួម ដើម្បីឲ្យមានថវិកាគ្រប់គ្រាន់ និងមិនចាំបាច់ពឹងពាក់លើអាហារកិច្ចផ្តល់ដោយប្តី ។

## ៣.៥ អំណាចមេបា សិទ្ធិទៅសួរសុខទុក្ខកូន និងអាហារកិច្ចផ្តល់ឲ្យកូន

ច្បាប់ចែងថា ក្នុងករណីលែងលះគ្នា ប្តីប្រពន្ធអាចសម្រេចថាភាគីម្ខាងណាអាចទទួលបានសិទ្ធិអំណាចមេបា ។ ប្រសិនបើគូភាគីមិនអាចឯកភាពគ្នាបាន តុលាការអាចធ្វើការសម្រេច[៥២] ។ អំណាចមេបារួមបន្ទាប់ពីលែងលះគ្នា មិនទាន់មានឡើយនៅកម្ពុជា គ្រាដែរប្រទេសប្រតិបត្តិប្រព័ន្ធច្បាប់ស៊ីវិលដទៃទៀតមាន ។ ចំណុចនេះមានសារសំខាន់ណាស់ចំពោះភាគីបុរសជាឪពុក ដែលភាគច្រើនមិនមែនជាអ្នកថែរក្សាកូន ។ ក្នុងករណីដ៏កម្រនេះ សមាជិកសភាកម្ពុជាហាក់បីដូចជាគាំទ្រស្ត្រីជាម្តាយ ។ ដើម្បីបន្ធូរបន្ថយដល់បញ្ហានេះ ច្បាប់តម្រូវឲ្យអ្នកដែលមានអំណាចមេបាត្រូវរាយការណ៍ជាប្រចាំ ឬពិភាក្សាជាមួយឪពុក ឬ ម្តាយ ដែលពុំមានអំណាចមេបា អំពីចំណុចដែលទាក់ទងនឹងកូនដូចជាការអប់រំ ការផ្លាស់ប្តូរទីសំណាក់ វិជ្ជាជីវៈ ឬ អាជីវកម្ម សកម្មភាពព្យាបាល ដែលទាក់ទងដល់អាយុជីវិតរបស់កូន ការចាត់ចែងទ្រព្យសម្បត្តិសំខាន់របស់កូន និងចំណុចសំខាន់ៗផ្សេងទៀត[៥៣] ។

ច្បាប់ក៏ផ្តល់សិទ្ធិទៅសួរសុខទុក្ខកូន និងអាហារកិច្ចកូនទៅដល់ឪពុក ឬ ម្តាយ ដែលពុំមានអំណាចមេបា ។ ជាគោលការណ៍ តុលាការស្របតាមរបៀបចូលជួបប្រាស្រ័យទាក់ទង និងសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូនបានកំណត់ដោយឪពុកម្តាយ ។ យ៉ាងណាមិញតុលាការមានសិទ្ធិសេរីភាពក្នុងការផ្លាស់ប្តូររបៀបរៀបចំនេះ[៥៤] ។ ឆន្ទានុសិទ្ធិរបស់តុលាការអាចប្រើប្រាស់បាន បើតុលាការទទួលស្គាល់ថាចាំបាច់ដើម្បីផលប្រយោជន៍របស់កូន ។

## ៣.៦ ការចាត់ចែងរក្សាការពារ

ដំណើរការនីតិវិធីលែងលះត្រូវការរយៈពេលយូរដើម្បីបញ្ចប់ ជាធម្មតា ត្រូវចំណាយពេលពី ៦ខែ ដល់ ១ឆ្នាំ[៥៥] ។ ដើម្បីគាំពារសិទ្ធិរបស់សហព័ទ្ធទាំងសងខាងក្នុងអំឡុងពេលលែងលះតុលាការ

---

[៥២] ក្រមរដ្ឋប្បវេណី, មាត្រា ១០៣៧ ។

[៥៣] ដូចខាងលើ មាត្រា ១១៤២ ។

[៥៤] ដូចខាងលើ មាត្រា ១១៤០ ។

[៥៥] ដំណើរការនីតិវិធីលែងលះជាទូទៅចំណាយពេលយូរជាងនេះទៅ ប្រសិនបើមានការបែកចែកទ្រព្យសម្បត្តិ ។

អាចធ្វើការចាត់ចែងរក្សាការពារតាមពាក្យសុំពីគូភាគីទាំងពីរ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។ ការចាត់ចែងរក្សាការពារមានដូចជា ការបំបែកលំនៅ អំណាចមេបា ការគ្រប់គ្រងថែរក្សាទ្រព្យសម្បត្តិ អាហារកាតព្វកិច្ចរបស់សហព័ទ្ធ ការចំណាយក្នុងគ្រួសារ សោហ៊ុយសម្រាប់ការសិក្សារបស់កូន ជាអាទិ៍[៥៦] ។ មាត្រានេះចែងយ៉ាងជាក់លាក់ ហើយចៅក្រមអាចធ្វើការសម្រេចចិត្តលើសិទ្ធិប្រើប្រាស់គេហដ្ឋានដោយគូភាគីម្ខាង សម្រាប់ទៅសួរសុខទុក្ខកូនជាប្រចាំ រួមទាំងការបង់ប្រាក់អាហារកិច្ចរបស់កូនប្រចាំខែទៅសហព័ទ្ធដែលទទួលបានអំណាចមេបា ។ ថ្វីបើច្បាប់មិនបានចែងច្បាស់លាស់ពីបញ្ហានេះ ការចាត់ចែងរក្សាការពារអាចមានសុពលភាពបាន នៅពេលដែលតុលាការធ្វើការសម្រេចចុងក្រោយលើបញ្ហាមួយចំនួន ជាពិសេសលើសាលក្រមលែងលះគ្នា ។

## ៤. អាពាហ៍ពិពាហ៍ និងការលែងលះដែលគ្មានសុពលភាពតាមផ្លូវច្បាប់

### ៤.១ អាពាហ៍ពិពាហ៍ដែលគ្មានសុពលតាមផ្លូវច្បាប់

នៅកម្ពុជា ប្តីប្រពន្ធជាច្រើនគូមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅការិយាល័យអាត្រានុកូលដ្ឋាន ពីព្រោះពួកគេយល់ថានីតិវិធីចុះបញ្ជីអាពាហ៍ពិពាហ៍មានលក្ខណៈលំបាក ។ ប្តីប្រពន្ធភាគច្រើនឆ្លងកាត់តែដំណាក់កាលទីមួយនៃនីតិវិធីចុះអាពាហ៍ពិពាហ៍ គឺការដាក់ពាក្យសុំច្បាប់អាពាហ៍ពិពាហ៍ និងផ្សាយជាសាធារណៈតែប៉ុណ្ណោះ ដោយមិនបានខ្វល់ខ្វាយចុះសំបុត្រអាពាហ៍ពិពាហ៍នៅសាលាសង្កាត់នោះទេ[៥៧] ។ ប្រជាជនខ្មែរភាគច្រើន ជាពិសេសនៅតាមជនបទ ពុំដឹងអំពីអត្ថប្រយោជន៍នៃការចុះសំបុត្រអាពាហ៍ពិពាហ៍ តែបែជាផ្តល់តម្លៃច្រើនទៅលើការរៀបការតាមព្រះពុទ្ធសាសនា ។ សម្រាប់ប្រជាជនខ្មែរ ការរៀបការតាមប្រពៃណីបង្កើតបានជាចំណងអាពាហ៍ពិពាហ៍ មិនមែនការចុះបញ្ជីអត្រានុកូលដ្ឋាននោះទេ ។ បន្ថែមពីលើការខ្វះខាតការយល់ដឹងផ្នែកច្បាប់អំពីសារសំខាន់នៃការចុះសំបុត្រអាពាហ៍ពិពាហ៍គឺបញ្ហាតម្លៃ ។ ថ្វីបើតម្លៃចុះបញ្ជីជាផ្លូវការនៅក្រុមប្រឹក្សាសង្កាត់ថ្លៃបំផុតគឺ ៤០០ រៀល (តិចជាង ០,១០ ដុល្លារសហរដ្ឋអាមេរិក) មានការរាយការណ៍ថា ប្តីប្រពន្ធមួយចំនួនបានបង់ដល់ទៅ ៤០,០០០ រៀល (ប្រហែល ១០ ដុល្លារសហរដ្ឋអាមេរិក)[៥៨] ។

---

[៥៦] ក្រមរដ្ឋប្បវេណី, មាត្រា ៩៨៣ ។

[៥៧] សូមមើល UNDP, កំណត់ចំណាំលេខ ៣៤, ទំព័រទី ៨០ ។

[៥៨] កំណត់ចំណាំពីវគ្គសិក្ខាសាលាស្តីអំពីសិទ្ធិទទួលបានការលែងលះរបស់ស្ត្រី រៀបចំដោយជំនួយផ្នែកច្បាប់កម្ពុជា នៅប្រទេសកម្ពុជា (មិនា ១៧ ២០១០) (on file with author) ។

ការខកខានមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍បណ្តាលឲ្យប្តីប្រពន្ធជាច្រើនគូមិនបានរៀបអាពាហ៍ពិពាហ៍ស្របតាមច្បាប់ ។ មិនមានស្ថិតិស្តីអំពីចំនួន "អាពាហ៍ពិពាហ៍ដែលគ្មានសុពលភាពតាមផ្លូវច្បាប់" នោះទេ ។ ទោះបីជាមានការជឿជាក់ថាប្តីប្រពន្ធភាគច្រើនបានចុះសំបុត្រអាពាហ៍ពិពាហ៍ហើយក៏ដោយ[៥៩] ប្តីប្រពន្ធមួយចំនួនមិនទាន់បានធ្វើនៅឡើយ ។ មេធាវីមួយចំនួននិយាយថា ២០ ភាគរយនៃអតិថិជនរបស់ពួកគេនៅតាមជនបទបានចុះសំបុត្រអាពាហ៍ពិពាហ៍ ។

ការអាកខាននេះមានផលប៉ះពាល់ដល់សិទ្ធិរបស់ស្ត្រី ជាពិសេសស្ត្រីជាប្រពន្ធដែលកំពុងព្យាយាមលែងលះ ។ សិទ្ធិរបស់ស្ត្រីលើទ្រព្យសម្បត្តិរួម និងអាហារកាតព្វកិច្ចមិនអាចធានាបាន ពីព្រោះពួកគេមិនត្រូវបានចាត់ទុកថារៀបអាពាហ៍ពិពាហ៍ស្របច្បាប់ ដូច្នេះ ពួកគេមិនទទួលបានសិទ្ធិជាកម្មសិទ្ធិករលើទ្រព្យសម្បត្តិរបស់**ប្តីដែលមិនស្របតាមផ្លូវច្បាប់**ដែរ ។ លើសពីនេះទៅទៀត សិទ្ធិអំណាចមេបាក៏បាត់បង់ ពីព្រោះប្តីមិនមែនជាឪពុកស្របច្បាប់របស់កូនពួកគេទេ ។ ឧទាហរណ៍មួយចំនួននឹងលើកឡើង ដើម្បីបង្ហាញពីភាពធ្ងន់ធ្ងរនៃបញ្ហានេះ ។

> ឧទាហរណ៍ ប្តីប្រពន្ធមួយគូមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅក្រុមប្រឹក្សាសង្កាត់ ហើយប្តីបានទិញដីមួយប្លង់ក្នុងអំឡុងពេលរៀបការ ដោយប្រើប្រាស់ប្រាក់ចំណូល និងប្រាក់សន្សំរកបានក្នុងអំឡុងពេលរៀបការដែរ ។ ប្តីបានចុះឈ្មោះខ្លួនជាកម្មសិទ្ធិករតែម្នាក់នៃដីនេះ ។
>
> ប្រពន្ធដែលមិនស្របតាមផ្លូវច្បាប់ម្នាក់នេះពុំមានសិទ្ធិទទួលបានដី ដូចប្តីប្រពន្ធដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ ។
>
> ឧទាហរណ៍ ប្តីប្រពន្ធមួយគូមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅក្រុមប្រឹក្សាសង្កាត់ ហើយពួកគេមានកូនពីរនាក់ ។

---

[៥៩] កំណត់សម្គាល់ធ្វើឡើងដោយលោក ចាន់ សុវណ្ណា មកពីក្រសួងមហាផ្ទៃ ក្នុងវគ្គសិក្ខាសាលារៀបចំដោយជំនួយផ្នែកច្បាប់ ។

> កូនទាំងពីរគឺជាកូនឥតខាន់ស្លារបស់ប្ដី ។ ប្ដីនឹងមានទំនួលខុសត្រូវចំពោះកូនទាំងពីរ ប្រសិនបើទទួលស្គាល់កូនដោយស្ម័គ្រចិត្ត[៦០] ឬ កូនអាចដាក់ពាក្យបណ្ដឹងទាមទារឲ្យទទួលស្គាល់[៦១] ។

ដូចដែលបានបង្ហាញដោយឧទាហរណ៍ខាងលើ ផលវិបាកផ្នែកច្បាប់ចំពោះអាពាហ៍ពិពាហ៍មិនបានចុះបញ្ជីបង្កឲ្យមានបញ្ហាធ្ងន់ធ្ងរដល់ប្ដីប្រពន្ធ ដែលប្រហែលជាចង់បានអាពាហ៍ពិពាហ៍ទទួលស្គាល់ដោយច្បាប់ ប៉ុន្តែអាកខានមិនបានទៅចុះបញ្ជីអាពាហ៍ពិពាហ៍នៅក្រុមប្រឹក្សាសង្កាត់ទៅវិញ ។

ដោយសារតែបញ្ហានេះកើតមានឡើងមានជាប្រចាំនៅតុលាការ វិស័យយុត្តិធម៌ រួមទាំងមន្ត្រីរដ្ឋាភិបាលកម្ពុជាបានព្យាយាមដោះស្រាយបញ្ហាច្បាប់នេះ តាមរយៈមធ្យោបាយដ៏មានប្រសិទ្ធភាពមួយចំនួន ។ ចៅក្រមមួយចំនួនសុខចិត្តទទួលស្គាល់អាពាហ៍ពិពាហ៍ដែលគ្មានសុពលភាពស្របតាមផ្លូវច្បាប់ជាអាពាហ៍ពិពាហ៍ស្របច្បាប់ និងផ្តល់សាលក្រមលែងលះអនុលោមទៅតាមប្រព័ន្ធដែលកំណត់ដោយច្បាប់[៦២] ក្នុងករណីដែលមានភ័ស្តុតាងបង្ហាញថាប្ដីប្រពន្ធរៀបការតាមប្រពៃណី ។ ហេតុផលរបស់ចៅក្រមប្រហែលជាអាចផ្អែកលើមាត្រា ៩៨៥ នៃក្រមរដ្ឋប្បវេណី ដែលចែងថាប្រសិនបើគ្រាន់តែមានវិការៈបន្តិចបន្តួចលើនីតិវិធីប៉ុណ្ណោះ អានុភាពនៃអាពាហ៍ពិពាហ៍មិនត្រូវបានរារាំង ។ ទោះបីជាការចាត់ទុកថាការអាកខានមិនបានចុះអាពាហ៍ពិពាហ៍ជា "វិការៈតែបន្តិចបន្តួច" គឺជាមន្ទិលសង្ស័យមួយក៏ដោយ ដំណោះស្រាយចំពោះចន្លោះប្រហោងនៃការគាក់តែងច្បាប់មានប្រសិទ្ធភាព និងប្រកបដោយមនុស្សធម៌ ។ ចៅក្រមមួយចំនួនផ្សេងទៀតជ្រើសរើសយកនីតិវិធីជាផ្លូវការ ដោយមិនចេញសាលក្រមលែងលះ បើអាពាហ៍ពិពាហ៍មិនស្របតាមច្បាប់ ។

> គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទបានរកឃើញ និងព្យាយាមដោះស្រាយពីបញ្ហានេះកាលពីឆ្នាំ ២០១៣ :

---

[៦០] ក្រមរដ្ឋប្បវេណី, មាត្រា ៩៩៣ ។

[៦១] សូមមើលខាងលើ មាត្រា ១០០១ ។

[៦២] សូមមើល UNDP, កំណត់ចំណាំលេខ ៣៨, ទំព័រ ១២១ និង ១៨១ ។

គណៈកម្មាធិការក៏បានផ្តល់អនុសាសន៍ទៅដល់រដ្ឋភាគី (កម្ពុជា) ឲ្យចាត់វិធានការដើម្បីជួយសម្រួលដល់ការរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីឲ្យទៅជាស្របច្បាប់ ដោយធានាថាការចុះសំបុត្រអាពាហ៍ពិពាហ៍មានតម្លៃសមរម្យ និងមិនស្មុគស្មាញ[៦៣] ។

## ៤.២ ការលែងលះដែលគ្មានសុពលភាពតាមផ្លូវច្បាប់

ផ្ទុយនឹង *"អាពាហ៍ពិពាហ៍ដែលគ្មានសុពលភាពតាមផ្លូវច្បាប់"* គឺ *"ការលែងលះដែល គ្មានសុពលភាពតាមផ្លូវច្បាប់"* ។ *ការលែងលះដែលគ្មានសុពលភាពតាមផ្លូវច្បាប់*តែងតែកើតមានឡើងដែលបណ្តាលឲ្យមានចន្លោះប្រហោងនៃការគាត់តែងច្បាប់ដែរ ។ ការលែងលះដែលគ្មានសុពលភាពស្របតាមផ្លូវច្បាប់កើតឡើង នៅពេលប្តីប្រពន្ធដែលរៀបអាពាហ៍ពិពាហ៍ស្របច្បាប់មិនបានទទួលការលែងលះស្របច្បាប់ពីតុលាការ ។ ជាទូទៅបណ្តឹងវិវាទនៅ តុលាការកម្ពុជាមានលក្ខណៈស្មុគស្មាញ ដូច្នេះប្រជាពលរដ្ឋភាគច្រើនព្យាយាមមិនទៅតុលាការ ។ ក្នុងឆ្នាំ ២០១៤ ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទី ៩៧ ក្នុងចំនោមប្រទេស ៩៩ ដែលសិទ្ធិទទួលបានយុត្តិធម៌នៅអន់ខ្សោយ[៦៤] ។ ភាពអន់ខ្សោយនៃសិទ្ធិទទួលបានយុត្តិធម៌គឺជាឧបសគ្គដ៏ធ្ងន់ធ្ងរមួយរារាំងដល់ការលែងលះនៅប្រទេសកម្ពុជា ។

បញ្ហាបន្ថែមពីលើឧបសគ្គនេះគឺច្បាប់ទាក់ទិននឹងការលែងលះបង្ហាញអំពីវប្បធម៌នៃសង្គមកម្ពុជា និងការអាប់ឱនកិត្តិយសរបស់សហព័ទ្ធបន្ទាប់ពីលែងលះ រួមមានឧបសគ្គក្នុងការទទួលបានសាលក្រមលែងលះ ។ ទីមួយ នីតិវិធីមានរយៈពេលវែង និងពិបាក[៦៥] ។ តាមការអនុវត្តជាក់ស្តែង

ប្តីប្រពន្ធត្រូវទៅតុលាការពី ៣ ទៅ ៥ ដង មុនពេលតុលាការប្រកាសសាលក្រមលែងលះ ។

---

[៦៣] សេចក្តីអង្កេតការសន្និដ្ឋានរបស់គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីនៅប្រទេសកម្ពុជា, កំណត់ចំណាំលេខ ៩ ។

[៦៤] World Justice Project Rule of Law Index (២០១៤), ទំព័រទី ៨០, មាននៅលើគេហទំព័រ http://worldjusticeproject.org/rule -of-law-index ។

[៦៥] សូមមើលក្រមនីតិវិធីរដ្ឋប្បវេណីនៃប្រទេសកម្ពុជា, គន្ថីទី ២ ៖ នីតិវិធីនៃការជម្រះក្តីលើកទី ១ (២០០៦), មាននៅលើគេហទំព័រ http://cambodiabusinesscorner.wordpress.com/2013/01/05/civil-code-2007/ ។

ទីពីរ នីតិវិធីលែងលះរួមមានការសាកល្បងធ្វើការផ្សះផ្សាររវាងប្តីប្រពន្ធជាច្រើនដង ដែលធ្វើឡើងដោយក្រុមប្រឹក្សាឃុំសង្កាត់ និងតុលាការ[៦៦] ។ ច្បាប់ថែមទាំងអនុញ្ញាតឲ្យតុលាការនៅតែអាចទាមទារឲ្យមានការផ្សះផ្សា ទោះបីជាសហព័ទ្ធទាំងពីរទទូចចង់បានការលែងលះខ្លាំងយ៉ាងណា ក៏ដោយ[៦៧] ។ ការអនុវត្តនេះខុសពីគោលការណ៍ផ្សះផ្សាអន្តរជាតិ ដែលចែងថាគូភាគីទាំងពីរត្រូវតែស្ម័គ្រចិត្តចូលរួមនីតិវិធីផ្សះផ្សា ។ ជាធម្មតា ប្រពន្ធគឺជាអ្នកដាក់ពាក្យប្តឹងសុំលែងលះ ហើយវាគឺរឿងមួយពិបាកណាស់សម្រាប់ស្ត្រីខ្មែរ ក្នុងការមិនអើពើចំពោះ គំនាបមកពីការព្យាយាមផ្សះផ្សារបស់តុលាការ ហើយចៅក្រមភាគច្រើនគឺជាបុរស ដែលទំនងជាបដិសេធការសុំលែងលះ[៦៨] ។

ទីបី ដោយសារតែនីតិវិធីលែងលះមានការលំបាកស្មុគស្មាញ គូភាគីត្រូវការអ្នកតំណាងផ្នែកច្បាប់ ដែលបណ្តាឲ្យមានបញ្ហាលុយកាក់រាំងដល់ការលែងលះ ។ ទោះបីជាច្បាប់ចែងថាគូភាគីទាំងពីរអាចតំណាងឲ្យខ្លួនឯងបាន ប៉ុន្តែសម្រាប់អ្នកដែលគ្មានជំនាញច្បាប់ ការដាក់ពាក្យប្តឹងសុំលែងលះគឺលំបាកខ្លាំង ។ នាពេលបច្ចុប្បន្ន ប្រហែលជាមេធាវីចំនួន ៧២០ រូប កំពុងអនុវត្តច្បាប់នៅកម្ពុជា ដូច្នេះអាត្រានៃមេធាវីមួយម្នាក់គឺសម្រាប់ប្រជាពលរដ្ឋ ១៩,០០០ នាក់ បើប្រៀបធៀបទៅប្រទេសហូឡង់ មេធាវីមួយម្នាក់សម្រាប់ប្រជាពលរដ្ឋ ១,០០០ នាក់ ឬ សម្រាប់ប្រជាពលរដ្ឋ ២៦៥[៦៩] នៅសហរដ្ឋអាមេរិក[៧០] ។ មេធាវីនៅកម្ពុជាមិនត្រឹមតែមានចំនួនតិច ប៉ុន្តែក៏មានតម្លៃថ្លៃ ហើយមានតែមេធាវី ១១៩ រូបតែប៉ុណ្ណោះដែលធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលក្នុងឆ្នាំ ២០១០[៧១] ដើម្បីផ្តល់សេវាកម្ម ។ លើសពីនេះទៅទៀត មេធាវីភាគច្រើនធ្វើការនៅទីក្រុងភ្នំពេញ ឬ

---

[៦៦] សូមមើលក្រមរដ្ឋប្បវេណី, មាត្រា ៩៨២ (២), និងមាត្រា៩៨៤ ។

[៦៧] ដូចខាងលើ, មាត្រា ៩៨៧ ។

[៦៨] សូមមើល Cambo, កំណត់ចំណាំលេខ ២៤, ទំព័រទី ១៥ ។

[69] S.L.Peters, et al., *សរសេរអត្ថបទមួយដែលមានចំណងជើងថា* Raad voor Rechtsbijstand: Monitor Gesubsideerde Rechtsbijstand (២០១១), មាននៅលើគេហទំព័រ http://rvr.turnpages.nl/DS/public/slot00008/pdf/compleet.pdf ។

[៧០] សូមមើល http://wiki.answers.com/Q/What_country_in_the_world_has_most_lawyers_per_capita ។

[៧១] Christoph Sperfeldt et al., *សរសេររបាយការណ៍មួយដែលមានចំណងជើងថា* *Legal Aid Services in Cambodia: Report of a Survey Among Legal Aid Providers Cambodian Human Rights Action*

ក៏ទីក្រុងធំៗ មិនមែននៅទីរួមខេត្តឆ្ងាយៗនោះទេ។ ប្រសិនបើស្ត្រីម្នាក់ចង់លែងលះ ប៉ុន្តែមិនអាចរកបានមេធាវីផ្តល់សេវាសាធារណៈ ស្ត្រីម្នាក់នេះត្រូវជួលមេធាវី និងបង់ថ្លៃចំណាយផ្សេងទៀតដូចជា ៥៥,០០០ រៀល (ប្រហែល ១៣.៧៥ ដុល្លារសហរដ្ឋអាមេរិក) សម្រាប់ប្រាក់ប្រដាប់ក្តីតុលាការ ៥,០០០ រៀល (ប្រហែល ១.២៥ ដុល្លារសហរដ្ឋអាមេរិក) សម្រាប់ពន្ធដាក់ពាក្យសុំ និង ៥,០០០ រៀល បន្ថែមសម្រាប់សេចក្តីស្នើសុំទៅតុលាការផ្សេងៗ ។ លើសពីនេះទៀតគឺសោហ៊ុយធ្វើដំណើរទៅតុលាការតាមការស្នើសុំពី ២ ទៅ ៥ ដង សម្រាប់ករណីលែងលះ ។

ឧបសគ្គមួយទៀតចំពោះស្ត្រីចង់បានការលែងលះគឺ សមាជិកភាគច្រើននៃក្រុមប្រឹក្សាឃុំសង្កាត់ជាបុរស (៨២ ភាគរយ)[៧២] ហើយចៅក្រមភាគច្រើនក៏ជាបុរសដែរ (៩១,៥ ភាគរយ)[៧៣] ។ វប្បធម៌ខ្មែរមិនជំរុញឲ្យស្ត្រីស្តីនិយាយបើកចំហជាពិសេសនៅទីសាធារណៈ ឬតុលាការ ។ មានស្ត្រីខ្មែរតំរូបប៉ុន្មានម្នាក់ដែរ ដែលហ៊ានចេញមុខជាសាធារណៈការពារសិទ្ធិរបស់ខ្លួន ទោះបីជាទង្វើនេះផ្ទុយស្រឡះនឹងចរិយាសម្បត្តិសមរម្យរបស់ស្ត្រីកំណត់ដោយវប្បធម៌ខ្មែរ ។ ហេតុដូច្នេះ វាមិនមែនជារឿងគួរឲ្យភ្ញាក់ផ្អើលទេ ដែលស្ត្រីភាគច្រើនចង់លែងលះមិនជ្រើសរើសធ្វើការលែងលះតាមតុលាការ ។ ជាធម្មតា ក្រុមប្រឹក្សាឃុំសង្កាត់គឺជាកន្លែងទីមួយ និងក៏ជាកន្លែងចុងក្រោយបំផុតសម្រាប់សហព័ទ្ធចង់ធ្វើបានការលែងលះ ។

ការលែងលះដែលគ្មានសុពលភាពតាមផ្លូវច្បាប់អាចបណ្តាឲ្យមានផលវិបាកធ្ងន់ធ្ងរ ។

---

*Committee (CHRAC)* (វិច្ឆិកា ២០១០), មាននៅលើគេហទំព័រ http://cambodia.ohchr.org/WebDOCs/DocProgrammes/CHRAC_Legal_aid_survey_Nov_2012_Eng.pdf ។

[៧២] មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា, Joint Press Release on Results of the Commune/Sangkat Council Elections 2012: Further Efforts Required to Achieve Quantitative and Qualitative Female Representation in Politic in Cambodia (១១ កក្កដា ២០១២)មាននៅលើគេហទំព័រ http://iknowpolitcs.org/en/2012/07/joint-press-release -result-commune-council-election-2012-further-effortss-required-achieve (ទាញយកនៅថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១៤) ។

[៧៣] អង្គការយេនឌ័រ និងអភិវឌ្ឍន៍ ដើម្បីកម្ពុជា (GAD/C), et al., CSO Report on Cambodian Gender Issues (៨ មេសា ២០០៩), មាននៅលើគេហទំព័រ http://lib.ohchr.org/HRBodies/UPR/Documents/Session6/KH/JS4_KHM_UPR_S06_2009_ JointSubmission4.pdf(ទាញយកនៅថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០១៤) ។

*ឧទាហរណ៍ ប្ដីប្រពន្ធមួយគូមិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ ។ ពីរឆ្នាំក្រោយ ប្ដីបានចាកចោលប្រពន្ធ ។ ពួកគេមិនបានទទួលសាលក្រមលែងលះពីតុលាការនោះទេ ។ ២០ ឆ្នាំក្រោយមក ប្ដីបានត្រឡប់មកវិញ បន្ទាប់ពីបានដឹងថាប្រពន្ធដែលខ្លួនបានបោះបង់ ក្លាយទៅជាអ្នកដំនួញដ៏ជោគជ័យម្នាក់ បានស្នើសុំការលែងលះ និងទាមទារទ្រព្យសម្បត្តិពាក់កណ្ដាលរបស់ប្រពន្ធ ។*

សន្មតថា ប្ដីប្រពន្ធមួយគូនៅក្នុងឧទាហរណ៍ខាងលើពុំបានធ្វើកិច្ចព្រមព្រៀងមុនអាពាហ៍ពិពាហ៍ ដែលចែងអំពីការមិនអនុវត្តន៍តាមប្រព័ន្ធទ្រព្យសម្បត្តិរួមកំណត់ដោយច្បាប់ប្ដីអាចមានឱកាសឈ្នះក្ដីនៅតុលាការ ។ ប៉ុន្តែ ប្រពន្ធអាចទាមទារឲ្យតុលាការកាត់បន្ថយចំណែករបស់ប្ដីឲ្យតិចជាងពាក់កណ្ដាល ដោយផ្អែកតាមកាលៈទេសៈមួយចំនួន[៧៨] ។

*ឧទាហរណ៍ ប្ដីប្រពន្ធមួយគូបានចុះសំបុត្រអាពាហ៍ពិពាហ៍ ។ ពីរឆ្នាំក្រោយមក ប្ដីបានចាកចោលប្រពន្ធ ។ ប្រពន្ធបានធ្វើការលែងលះតាមរយៈក្រុមប្រឹក្សាឃុំសង្កាត់ ហើយការលែងលះនេះគ្មានសុពលភាពតាមផ្លូវច្បាប់ ក្រោយមក ប្រពន្ធរៀបការជាថ្មីជាមួយមិត្តរួមថ្នាក់ចាស់ ។ ពួកគេទាំងពីរបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅក្រុមប្រឹក្សាឃុំសង្កាត់ ។*

ប្ដីដើមអាចចោទប្រកាន់ប្រពន្ធពីបទទ្វេពន្ធភាព និងដាក់ពាក្យបណ្ដឹងជាមួយព្រះរាជអាជ្ញាដោយផ្អែកលើមូលដ្ឋានថាពួកគេមិនបានលែងលះស្របច្បាប់នោះទេ ដោយសារតែគ្មានដីកាលែងលះពីតុលាការ ។

*ឧទាហរណ៍ ប្ដីប្រពន្ធមួយគូបានចុះសំបុត្រអាពាហ៍ពិពាហ៍ ។ ពីរឆ្នាំក្រោយមក ប្ដីបានចាកចោលប្រពន្ធ ។ ប្រពន្ធបានធ្វើការលែងលះតាមរយៈក្រុមប្រឹក្សាឃុំសង្កាត់ ហើយការលែងលះនេះគ្មានសុពលភាពតាមផ្លូវច្បាប់ ក្រោយមក ប្រពន្ធរៀបការជាថ្មីជាមួយមិត្តរួមថ្នាក់ចាស់ ។ ពួកគេទាំងពីរនាក់មិនបានចុះបញ្ជីអាពាហ៍ពិពាហ៍ និងមានកូនបួននាក់ ។*

[៧៨] សូមមើលក្រមរដ្ឋប្បវេណី, មាត្រា ៩៨០ (២) ។

ប្ដីដើមនឹងត្រូវបានចាត់ទុកថាជាឪពុកស្របច្បាប់របស់កូនទាំងបួននាក់នេះ[៧៥] ។

ដូចទៅនឹងអាពាហ៍ពិពាហ៍ដែលគ្មានសុពលភាពតាមផ្លូវច្បាប់ដែរ វិស័យយុត្តិធម៌ និងមន្ត្រីរដ្ឋាភិបាលបានព្យាយាមរកមធ្យោបាយ ដើម្បីដោះស្រាយជាមួយផលវិបាកផ្លូវច្បាប់នៃការលែងលះដែលគ្មានសុពលភាព ។ ក្រុមប្រឹក្សាឃុំសង្កាត់រកបានដំណោះស្រាយដ៏មានប្រសិទ្ធភាពមួយគឺការចេញដីកាបំបែកលំនៅប្ដីប្រពន្ធ[៧៦] ។ ការចេញដីកានេះមិនមានអត្ថន័យស្របច្បាប់នោះទេ ពីព្រោះមិនបានផ្អែកលើច្បាប់ ។ ទោះជាដូច្នេះក្ដី តាមការអនុវត្តជាក់ស្ដែង ក្រុមប្រឹក្សាឃុំសង្កាត់នៅតែអនុញ្ញាតឲ្យប្ដីប្រពន្ធរៀបការសាជាថ្មី បន្ទាប់ពីទទួលបានដីកាបំបែកលំនៅ ។

មន្ត្រីសុរិយោដីក៏យល់ព្រមចំពោះផ្នែកខ្លះនៃមធ្យោបាយដ៏មានប្រសិទ្ធភាពមួយនេះដែរ ។ យោងទៅតាមគោលការណ៍ណែនាំស្ដីពីការវិនិច្ឆ័យលើការចុះបញ្ជីក្បាលដីឆ្នាំ ២០០៤ (2004 Land Adjudication Guideline) ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធទទួលស្គាល់ការលែងលះដែលគ្មានសុពលភាពតាមផ្លូវច្បាប់ ក្នុងករណីដែលដីកាបំបែកលំនៅប្ដីប្រពន្ធចេញដោយក្រុមប្រឹក្សាឃុំសង្កាត់បញ្ជាក់អំពីការបែកចែកទ្រព្យសម្បត្តិ ។ ហេតុដូច្នេះ មន្ត្រីសុរិយោដីអាចនឹងចុះបញ្ជីដីដោយឈ្មោះសហព័ទ្ធតែម្នាក់បាន ប្រសិនបើសហព័ទ្ធនេះមានដីការបំបែកលំនៅប្ដីប្រពន្ធ ។ ប៉ុន្តែ មន្ត្រីសុរិយោដីទទួលស្គាល់អាពាហ៍ពិពាហ៍ដែលគ្មានសុពលភាពតាមផ្លូវច្បាប់សម្រាប់តែប្ដីប្រពន្ធណា ដែលមិនបានរៀបការស្របច្បាប់តែប៉ុណ្ណោះ ។ ចំពោះប្ដីប្រពន្ធដែលរៀបការស្របច្បាប់ មន្ត្រីសុរិយោដីទាមទារឲ្យមានការបង្ហាញ ដីកាលែងលះពីតុលាការ[៧៧] ។

## ៤.៣. ភាពខុសគ្នារវាងច្បាប់ និងសង្គមពិត

ដើមហេតុចម្បងនៃបញ្ហាការរៀបអាពាហ៍ពិពាហ៍ និងលែងលះដែលគ្មានសុពលភាពតាមផ្លូវច្បាប់ គឺដោយសារច្បាប់ជាច្រើននៅពុំទាន់បានយកទៅអនុវត្តដោយប្រសិទ្ធភាពនៅតាមកម្រិតមូលដ្ឋាន ។ ដោយសារតែភាពក្រីក្រ ការគ្រប់គ្រងមិនបានល្អ និងភាពមិនទទួលបានយុត្តិធម៌ប្ដីប្រពន្ធ

---

[៧៥] សូមមើល id. មាត្រា ៩៨៨ ។

[៧៦] សូមមើល UNDP, កំណត់ចំណាំលេខ ៣៨, ទំព័រទី ៨០ ។

[៧៧] សូមមើល Mehrak Mehrvar et al., និពន្ធអត្ថបទមួយដែលមានចំណងជា *Women’s Perspective: A Case Study of Systematic Land Registration in Cambodia* (កក្កដា ២០០៨), ទំព័រទី ១២, មាននៅលើគេហទំព័រ www.kh.boell.org/downloads/CambodianWomensPerspectives_EN.pdf ។

ជួបខបសគ្គជាច្រើន នៅពេលចុះសំបុត្រអាពាហ៍ពិពាហ៍នៅក្រុមប្រឹក្សាឃុំសង្កាត់ ក៏ដូចជាស្នើសុំការលែងលះពីតុលាការ ។ យុទ្ធនាការលើកកម្ពស់ការចុះសំបុត្រអាពាហ៍ពិពាហ៍គួរតែមានធ្វើឡើង ដូចជាយុទ្ធនាការចុះសំបុត្រកំណើតដែលរៀបចំឡើងដោយអង្គការយូណេសស្កូនៅកម្ពុជា ។ ទោះបីជាអាពាហ៍ពិពាហ៍ទាំងអស់នៅកម្ពុជាបានចុះបញ្ជីក៏ដោយ ប្រព័ន្ធតុលាការនៅក្នុងប្រទេសមួយនេះមិនទាន់ត្រៀមខ្លួនរួច រាល់ក្នុងការដោះស្រាយការហូរចូលបណ្តឹងលែងលះដ៏ទៅរាប់ពាន់នៅឡើយ ។ មុខងាររបស់ប្រព័ន្ធ តុលាការកម្ពុជាជួបការលំបាក ដោយសារតែមានរឿងក្តីច្រើនពេក ខ្វះសមត្ថភាព និងបញ្ហាពុក រលួយ ហើយស្ថានការណ៍នេះអាចនឹងបន្តទៅប៉ុន្មានទសវត្សរ៍ខាងមុខទៀត ។

## ៥. សេចក្តីសន្និដ្ឋាន និងការណែនាំ

បញ្ហាយេនឌ័រជាក់លាក់មួយចំនួនកើតចេញពីប្រព័ន្ធរៀបការកំណត់ដោយច្បាប់នៅកម្ពុជា មានដូចជាការរៀបអាពាហ៍ពិពាហ៍ជាមួយអនីតិជននៅតែមានកើតឡើងក្នុងកម្រិតដ៏ខ្ពស់មួយ ជាពិសេសនៅតាមជនបទ ទោះបីជាមានបទបញ្ញត្តិហាមប្រាមក៏ដោយ ។ ក្រសួងកិច្ចការនារីគួរតែព្យាយាមបញ្ឈប់ការរៀបការក្មេងស្រីអាយុតិចជាង ១៨ ឆ្នាំ តាមរយៈកម្មវិធីផ្សព្វផ្សាយ ។ បញ្ហាយេនឌ័រមួយទៀតគឺការហាមឃាត់មិនឲ្យស្ត្រីរៀបការម្តងទៀតក្នុងរយៈពេល ១២០ ថ្ងៃ បន្ទាប់ពីការលែងលះ ការហាមឃាត់នេះគឺជាការជ្រៀតជ្រៀងជីវិតឯកជនរបស់ស្ត្រីជាម្តាយដោយទទួលបានអត្ថប្រយោជន៍ច្បាប់តិចតួច ឬគ្មានសល់ពីប្តី ទោះបីជាប្តីនោះជាប្តីទីមួយ ឬទីពីរក៏ដោយ ។ បទបញ្ញត្តិនៃក្រមរដ្ឋប្បវេណីមួយនេះគួរតែពិនិត្យឡើងវិញ ។

ច្បាប់កម្ពុជាមានប្រព័ន្ធចុះបញ្ជីអាពាហ៍ពិពាហ៍ច្បាស់លាស់ និងប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិកំណត់ដោយច្បាប់ត្រឹមត្រូវមួយ ។ មានភាពមិនច្បាស់មួយចំនួនក្នុងច្បាប់ទាក់ទិននឹងការព្រមព្រៀងរបស់សហព័ទ្ធម្ខាង ដើម្បីបែងចែកទ្រព្យសម្បត្តិរួម និងថាតើភាគីមួយណាត្រូវទទួលបន្ទុកលើសោហ៊ុយគ្រួសារ ។ តុលាការគួរតែបំភ្លឺបញ្ជាក់អំពីភាពមិនច្បាស់លាស់តាមរយៈច្បាប់ដែលយោងតាមការបកស្រាយពីមុនៗ និងធ្វើឲ្យច្បាប់បកស្រាយទាំងអស់នេះអាចរកបានដោយមហាជនទូទៅ ។ លើសពីនេះទៅទៀត ក្រសួងកិច្ចការនារី និងក្រសួងយុត្តិធម៌គួរតែចាត់វិធានការលើកកម្ពស់ការយល់ដឹងសាធារណជន និងការយល់ដឹងអំពីប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរួមកំណត់ដោយច្បាប់ ពីព្រោះចំណេះដឹងជាពិសេសទាក់ទិននឹងវិធានគ្រប់គ្រងកម្មសិទ្ធិដីហាក់បីដូចជានៅមានការខ្វះខាត ។ មានការផ្តល់ជាអនុសាសន៍ទៅដល់ក្រសួងកិច្ចការនារីឲ្យលើកកម្ពស់ការយល់ដឹងបន្ថែមទាក់ទងនឹងការរំលោភសេពសន្ថវៈ

ដោយសហព័ន្ធ និងផលវិបាកផ្នែកច្បាប់នៃបញ្ហានេះ ក៏ដូចជាផ្តល់ការគាំទ្រទៅដល់ស្ត្រីដែលត្រូវការជំនួយ ។ ជំនួយផ្នែកច្បាប់ត្រូវមានផ្តល់ឲ្យស្ត្រីដែលត្រូវប្រើប្រាស់ប្រព័ន្ធតុលាការ ។ ប៉ូលីស ព្រះរាជអាជ្ញា ចៅក្រមត្រូវតែទទួលការបណ្តុះបណ្តាលអំពីបញ្ហាទាំងអស់នេះ ដើម្បីប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាពដែលជាបញ្ហាមួយនាពេលបច្ចុប្បន្ននេះ ។

ច្បាប់កម្ពុជាផ្តល់សិទ្ធិគ្រប់គ្រាន់ទៅដល់ស្ត្រី (និងបុរស) ក្នុងករណីលែងលះស្របច្បាប់ រួមទាំងការបែកចែកទ្រព្យសម្បត្តិរួម សិទ្ធិគ្រប់គ្រងកូន សិទ្ធិទៅសួរសុខទុក្ខកូន និងការផ្តល់អាហារកិច្ចទៅដល់កូន ។ យ៉ាងណាមិញ ដើម្បីបន្ថែមការការពារលើសិទ្ធិស្ត្រី ប្រពន្ធដែលរកគេចចេញពីអាពាហ៍ពិពាហ៍ដែលមានអំពើហិង្សាដោយដាក់ពាក្យបណ្តឹងលែងលះ មិនគួរត្រូវបានចាត់ទុកថាជាអ្នកប្រព្រឹត្តិកំហុស និងទទួលបានសោធនអាហារកិច្ចប្តី ប្រសិនបើពួកគេត្រូវការ ហើយប្តីរបស់ពួកគេអាចមានមធ្យោបាយផ្តល់ឲ្យបាន ។ ទោះបីជាច្បាប់មិនបានចែងយ៉ាងជាក់លាក់ សិទ្ធិទទួលបានសោធននិវត្តន៍ពីប្តីគួរតែត្រូវបានចាត់ទុកជាផ្នែកមួយនៃទ្រព្យសម្បត្តិរួម ប៉ុន្តែគួរតែបង្ហាញពីរបៀបទទួលបាន និងនៅពេលណាសោធននិវត្តន៍គួរត្រូវបែងចែក ពេលណាគួរត្រូវផ្តល់ជូនតាមរយៈយុត្តិសាស្ត្រ និងឯកសារបោះពុម្ពផ្សាយ ។

ចំណុចដែលទទួលបានការព្រួយបារម្ភណ៍បំផុតនោះគឺការចុះសំបុត្រអាពាហ៍ពិពាហ៍ និងនីតិវិធីលែងលះនៅតុលាការ ។ នីតិវិធីទាំងពីរមានគុណវិបត្តិ និងពិបាកក្នុងការទទួលបាន ដោយសារតែមានតម្លៃថ្លៃ ។ ក្រសួងមហាផ្ទៃគួរតែលើកកម្ពស់ការយល់ដឹងរបស់ប្រជាជនទូទៅអំពីតម្លៃការចុះសំបុត្រអាពាហ៍ពិពាហ៍ជាផ្លូវការ ដើម្បីកុំឲ្យមានអំពើពុករលួយបន្ថែមទៀត ។ ក្រសួងយុត្តិធម៌ក៏គួរតែពិនិត្យនីតិវិធីលែងលះ ដើម្បីធ្វើឲ្យនីតិវិធីលែងលះងាយស្រួលយល់ ឬ ក៏បង្កើតមធ្យោបាយជំនួសងាយស្រួលមួយសម្រាប់ដីកាលែងលះស្របច្បាប់ ។ មធ្យោបាយផ្សេងទៀតគឺការរៀបចំសិន្និសីទទាក់ទិននឹងបញ្ហានេះ ដោយពិនិត្យឡើងវិញលើនីតិវិធីតុលាការផ្សេងៗក្នុងបណ្តាប្រទេស (អាស៊ី) ។ នីតិវិធីផ្សេងទៀតគួរតែមិនជាប់ពាក់ព័ន្ធនឹងតុលាការ ដែលបច្ចុប្បន្នមិនអាចផ្តល់លទ្ធភាពទទួលបានយុត្តិធម៌គ្រប់គ្រាន់ទៅដល់ប្រជាជនក្រីក្រ និងស្ត្រីបាន ។ ដើម្បីធ្វើឲ្យលទ្ធភាពទទួលបានយុត្តិធម៌តាមរយៈតុលាការប្រសើរឡើងសម្រាប់ស្ត្រីជាទូទៅ ស្ត្រីច្រើនជាងមុនគួរតែត្រូវបានតែងតាំងជាចៅក្រម ។ នៅពេលតុលាការមានចៅក្រមស្រីច្រើន បន្ទុកទៅលើស្ត្រីដែលទាមទារលែងលះក៏ត្រូវបានកាត់បន្ថយដោយសារតែមានការផ្លាស់ប្តូរអាកប្បកិរិយារបស់តុលាការចំពោះពួកគេ ។ មានអនុសាសន៍បន្ថែមទៀតថាចៅក្រមគួរតែទទួលបានគោលការណ៍ណែនាំថាពេលណាគួរតែព្យាយាមផ្សះផ្សា និងពេលណា

មិនគួរ ។ ឧទាហរណ៍ ការផ្សះផ្សាមិនសក្តិសម ក្នុងករណីដែលប្រពន្ធអះអាងថាមានអំពើហិង្សាក្នុងគ្រួសារ ។

អនុសាសន៍ទាំងអស់នេះនឹងបង្កើនលទ្ធភាពទទួលបានអាពាហ៍ពិពាហ៍ និងការលែងលះស្របច្បាប់នៅកម្ពុជា ។ ក្រសួងកិច្ចការនារីគួរតែលើកកម្ពស់ការយល់ដឹងរបស់សមាជិករាជរដ្ឋាភិបាលកម្ពុជាក៏ដូចជាសមាជិកសភាអំពីការកែប្រែថ្មីទាំងអស់នេះថាអាចនឹងមានការលែងលះច្រើនជាងមុនតាមជាក់ស្តែង ប៉ុន្តែក៏បាននាំមកនូវការការពារសិទ្ធិរបស់ស្ត្រីច្រើនជាងមុនក្នុងអំឡុងពេលលែងលះ ។